ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-Feb-2013, 20:59
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ/អ.ជ.ត.ក (១៨)

Case File/Dossier N°. 002/19-09-2007-ECCC-TC/SC (18)

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម **Chandra Nihal JAYASINGHE**
ចៅក្រម **Agniezska KLONOWIECKAMILART**
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម **Judge Florence Ndepele Mwachande MUMBA**
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម យ៉ា ណារិន

| | |
|---|---|
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ |
| ភាសាដើម៖ | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

# សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខផ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងស្ដីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១

**សហព្រះរាជអាជ្ញា**

ជា លាង

**សហមេធាវីជនជាប់ចោទ អៀង សារី**

អាង ឧត្តម

Andrew CAYLEY

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**ជនជាប់ចោទ**

អៀង សារី

ខៀវ សំផន

នួន ជា

Michael G. KARNAVAS

**សហមេធាវីជនជាប់ចោទ នួន ជា**

សុន អរុណ

Victor KOPPE

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN
Jacques VERGÈS

# មាតិកា

I. សេចក្តីផ្តើម ....................................................... 4

ក. សាវតារ ....................................................... 4

ខ. បណ្តឹងសាទុក្ខភ្លាមៗ ....................................................... 9

គ. ទឡ្ហីករណ៍ផ្ទាល់មាត់ ....................................................... 10

ឃ. សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ....................................................... 10

II. បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ ....................................................... 11

III. ភាពអាចទទួលយកបាន ....................................................... 12

ក. ភាពទាន់ពេលវេលា ....................................................... 13

ខ. វិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ....................................................... 16

IV. អង្គសេចក្តី ....................................................... 22

ក. ទម្រង់ ....................................................... 23

ខ. ខ្លឹមសារ ....................................................... 24

V. សេចក្តីសន្និដ្ឋាន ....................................................... 39

VI. ផ្នែកសេចក្តីសម្រេច ....................................................... 42

1. **អង្គជំនុំជម្រះតុលាការកំពូល** ("អ.ជ.ត.ក") នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ បានទទួលបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចស្ដីពីវិសាលភាពនៃការជំនុំជម្រះក្ដី នៅក្នុងសំណុំរឿង ០០២/០១ មានឧបសម្ពន្ធ I និងឧបសម្ពន្ធសម្ងាត់ II" ដែលបានដាក់នៅថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("បណ្ដឹងសាទុក្ខភ្លាមៗ")[1]។

# I. សេចក្ដីផ្ដើម

2. បណ្ដឹងសាទុក្ខនេះ ពាក់ព័ន្ធនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធផ្នែកខ្លះ នៃសំណើរបស់សហព្រះរាជអាជ្ញា សុំពង្រីកវិសាលភាពនៃការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿងបច្ចុប្បន្ននេះ ("សំណុំរឿង ០០២/០១" និង "សំណុំរឿង ០០២")[2]។

## ក. សាវតារ

3. នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ដោយចោទប្រកាន់ អៀង សារី, នួន ជា និង ខៀវ សំផន (រួមគ្នាទាំងអស់ "សហជនជាប់ចោទ") ពីបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ និងកំណត់នូវការចោទប្រកាន់ពាក់ព័ន្ធនឹងអង្គហេតុដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេច ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")[3] បន្ទាប់ពីមានបណ្ដឹងឧទ្ធរណ៍មួយចំនួនរួចមក អង្គបុរេជំនុំជម្រះបាន

---

[1] ឯកសារ E163/5/1/1 ។

[2] អនុស្សរណៈពីចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "សេចក្ដីជូនដំណឹងស្ដីពីសេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន" ឯកសារ E163/5 ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ ("សេចក្ដីសម្រេចដែលរងការជំទាស់") *ដែលសម្រេចលើ*សំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/១ ឯកសារ E163 ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ ("សំណើសុំពង្រីកវិសាលភាព") ។

[3] ដីកាដំណោះស្រាយ ឯកសារ D427 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ និងបានដាក់នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ ("ដីកាដំណោះស្រាយ")។ អៀង ធីរិទ្ធ ក៏ត្រូវបានចោទប្រកាន់រួមគ្នាជាមួយនឹងសហជនជាប់ចោទដែរ ប៉ុន្តែ បទចោទប្រឆាំងនឹងលោកស្រី ត្រូវបានបំបែកចេញ ហើយកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងលោកស្រី ដោយមិនកំណត់រយៈពេល ដោយសារតែ

តម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយដាក់ឲ្យស្ថិតនៅក្រោមការកែប្រែមួយចំនួន[4]។ អនុលោមតាមវិធាន ៧៩ និងវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង[5] អង្គជំនុំជម្រះសាលាដំបូងបានទទួលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបានបើកសវនាការបឋមចាប់ពីថ្ងៃទី ២៧ ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១[6]។ នៅសវនាការបឋម អង្គជំនុំជម្រះសាលាដំបូងបានប្រកាសអំពីលំដាប់លំដោយដែលអង្គជំនុំជម្រះមានបំណងចាប់ផ្តើមសវនាការលើអង្គសេចក្តីនៅក្នុងសំណុំរឿង ០០២[7]។

---

យល់ឃើញថាលោកស្រីពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ។ សូមមើល សេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E138/1/10 ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើការវាយតម្លៃឡើងវិញលើកាយសម្បទារបស់ អៀង ធីរិទ្ធ")។ សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ឯកសារ E138 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១("សេចក្តីសម្រេចលើ កាយសម្បទារបស់ អៀង ធីរិទ្ធ")។

[4] សូមមើល សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/2/15 និង D427/3/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ៖ សំអាងហេតុសម្រាប់ការបន្តការឃុំខ្លួនបណ្តោះអាសន្ន ឯកសារ D427/1/27 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ៖ សំអាងហេតុសម្រាប់ការបន្តការឃុំខ្លួនបណ្តោះអាសន្ន ឯកសារ D427/2/13 និង D427/3/13 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/4/15 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ឯកសារ D427/5/10 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/26 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/2/12 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/4/14 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ឯកសារ D427/5/9 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។

[5] វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក វិសោធនកម្មលើកទី៨ ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១ ("វិធានផ្ទៃក្នុង") ។

[6] សូមមើល ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E1/4.1 ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E1/5.1 ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E1/6.1 និងប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E1/7.1 (ទាំងអស់បញ្ចូលគ្នា "សវនាការបឋម")។

[7] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E1/4.1 ទំព័រ ៤-៨។

4. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ដោយអនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងបានបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ឲ្យទៅជាការជំនុំជម្រះដាច់ដោយឡែកពីគ្នា ដោយក្នុងការជំនុំជម្រះនីមួយៗ រួមមានផ្នែកជាក់លាក់នានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយនៅក្នុងការជំនុំជម្រះនីមួយៗ នឹងបញ្ចប់ដោយមានសាលក្រម និងការប្រកាសទោស ប្រសិនបើរកឃើញថា មានពិរុទ្ធភាព[8]។ ទាក់ទិននឹងការជំនុំជម្រះដំណាក់កាលដំបូង ពោលគឺសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា វិសាលភាពនៃការជំនុំជម្រះនេះ នឹងត្រូវបានកំណត់ត្រឹម៖ ប្រវត្តិ និងរចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ។ តួនាទីរបស់សហជនជាប់ចោទ មុន និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅពេលដែលតួនាទីរបស់ពួកគេត្រូវបានចាត់តាំង ការទទួលខុសត្រូវរបស់ពួកគេក្របខណ្ឌនៃសិទ្ធិអំណាចរបស់ពួកគេ និងខ្សែបណ្តាញទាក់ទង។ ការផ្លាស់ទីលំនៅប្រជាជនពីទីក្រុងភ្នំពេញក្នុងឆ្នាំ ១៩៧៥ ("ដំណាក់កាលទី១"។ ការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគកណ្តាល (ឧត្តរចាស់) និរតី បស្ចិម និងភូមិភាគបូព៌ា ចាប់ពីខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ ១៩៧៧ ("ដំណាក់កាលទី២") ហើយនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចំនួនប្រាំ (ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែងដោយហេតុផលសាសនា) ការជម្លៀសដោយបង្ខំ និង ការបាត់ខ្លួនដោយបង្ខំ) ប៉ុន្តែក្នុងវិសាលភាពដែលឧក្រិដ្ឋកម្មទាំងនេះពាក់ព័ន្ធទៅនឹងដំណាក់កាលទី១ និង ដំណាក់កាលទី២ប៉ុណ្ណោះ[9]។ អង្គជំនុំជម្រះសាលាដំបូងក៏បានចង្អុលបង្ហាញផងដែរថា៖

> អង្គហេតុពាក់ព័ន្ធនឹងសហករណ៍ ការដ្ឋាន មន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្ស ឬអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទីបី នឹងមិនត្រូវបានលើកយកមកដេញដោលនៅក្នុងការជំនុំជម្រះលើកដំបូងនេះទេ។ លើសពីនេះទៀត បទចោទប្រកាន់ទាំងអស់ ដូចជា បទប្រល័យពូជសាសន៍ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ត្រូវទុកដើម្បីលើកយកទៅដេញដោលនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីក្រោយៗទៀតនៅក្នុងសំណុំរឿង ០០២[10]។

---

[8] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ឯកសារ E124 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ("ដីកាបំបែកកិច្ចដំណើរការនីតិវិធី")។

[9] ដីកាបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ១, ៥។

[10] ដីកាបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៧។

5. នៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងការណ៍ដែលមិនត្រូវបានស្នើសុំឱ្យដាក់សារណាលើអង្គសេចក្តីនៃដីកាបំបែកកិច្ចដំណើរការនីតិវិធីមុនការចេញដីកានេះ[11] ហើយអាស្រ័យហេតុនេះបានស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញ និងកែប្រែដីកាបំបែកកិច្ចដំណើរការនីតិវិធីដែលថា វិសាលភាពនៃសំណុំរឿង ០០២/០១ រួមបញ្ចូលដំណាក់កាលទី១ ប៉ុន្តែមិនរាប់បញ្ចូលដំណាក់កាលទី២ និងដាក់បន្ថែមទីតាំងឧក្រិដ្ឋកម្មចំនួន៩ កន្លែង ដូចខាងក្រោមនេះ៖ ស្រុក ១២ និងកន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ។ មន្ទីរសន្តិសុខ ស-២១ រួមទាំងការបោសសម្អាតកម្មាភិបាលពីភូមិភាគឧត្តរថ្មី ភូមិភាគកណ្តាល (ឧត្តរចាស់) និងភូមិភាគបូព៌ាដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ប៉ុន្តែមិនរាប់បញ្ចូលការដ្ឋានព្រៃស។ ភូមិភាគឧត្តរ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង។ ការដ្ឋានសាងសង់វាលយន្តហោះកំពង់ឆ្នាំង និង សហករណ៍ត្រាំកក់[12]។ សហព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍ថា ដីកាបំបែកកិច្ចដំណើរការនីតិវិធី មិនស្ថិតនៅក្នុងផលប្រយោជន៍នៃយុត្តិធម៌ទេ ពីព្រោះបទចោទនានាដែលត្រូវបានជ្រើសយកសម្រាប់សំណុំរឿង ០០២/០១ ដែលសហព្រះរាជអាជ្ញាបានអះអាងថានឹងទំនងជាការជំនុំជម្រះតែមួយប៉ុណ្ណោះនៅក្នុងសំណុំរឿង ០០២[13] មិនតំណាងឱ្យអំពើឧក្រិដ្ឋរបស់សហជនជាប់ចោទ ដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[14] នឹងមិនលើកកម្ពស់នូវកំណត់ហេតុប្រវត្តិសាស្ត្រឱ្យបានត្រឹមត្រូវ[15] និងធ្វើឱ្យចុះថយនូវកេរដំណែលរបស់ អ.វ.ត.ក ក្នុង ការជួយជំរុញការផ្សះផ្សាជាតិ[16]។

---

[11] សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យពិចារណាឡើងវិញលើ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង" ឯកសារ E124/2 ចុះថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១ ("សំណើសុំឱ្យពិចារណាឡើងវិញ") កថាខណ្ឌ ២, ៧, ១៤-១៦, ២០-២៣។ សូមមើល សេចក្តីជូនដំណឹងអំពីសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យពិចារណាឡើងវិញលើពាក្យ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង" ឯកសារ E124/1 ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១ ("សេចក្តីជូនដំណឹងអំពីសំណើសុំឱ្យពិចារណាឡើងវិញ") កថាខណ្ឌ ៤(ខ)។

[12] សំណើសុំឱ្យពិចារណាឡើងវិញ កថាខណ្ឌ ១, ៣៦, ៤២-៤៣។ សហព្រះរាជអាជ្ញាក៏បានស្នើ ជាជម្រើសម្យ៉ាងទៀត សុំឱ្យអង្គជំនុំជម្រះសាលាដំបូង "ស្តាប់ទស្សនៈរបស់ភាគីនានា ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ អំពីទម្រង់ជំនួសនៃការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២"។ សូមមើល សំណើសុំពិចារណាឡើងវិញ កថាខណ្ឌ ៤៥។ សូមមើល ផងដែរ សំណើសុំពិចារណាឡើងវិញ កថាខណ្ឌ១។

[13] សំណើសុំពិចារណាឡើងវិញ កថាខណ្ឌ ៣, ១៥, ២៤-២៧, ២៩-៣០, ៣៦។

[14] សំណើសុំពិចារណាឡើងវិញ កថាខណ្ឌ ៣,១៨-១៩, ២១-២៤, ២៩-៣២, ៣៦, ៤៤។ សូមមើល ផងដែរ សេចក្តីជូនដំណឹងអំពីសំណើសុំពិចារណាឡើងវិញ កថាខណ្ឌ ៤(ក)។

[15] សំណើសុំពិចារណាឡើងវិញ កថាខណ្ឌ ៣, ៣២-៣៤។ សូមមើល ផងដែរ សេចក្តីជូនដំណឹងអំពីសំណើសុំពិចារណាឡើងវិញ កថាខណ្ឌ ៤(ក)។

នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំឱ្យពិចារណាឡើងវិញទាំងស្រុង[17]។

6. នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញា បានស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងពង្រីកវិសាលភាពសំណុំរឿង ០០២/០១ ដោយដាក់បន្ថែមទីតាំងឧក្រិដ្ឋកម្មចំនួនបីកន្លែង ក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មចំនួនប្រាំបួន ដែលបានស្នើឡើងកាលពីលើកមុន ពោលគឺ កន្លែងសម្លាប់មនុស្សនៅស្រុក១២ ("ស្រុក១២")[18] កន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ("ទួលពោធិ៍ជ្រៃ")[19] និងមន្ទីរសន្តិសុខ ស-២១ (រួមជាមួយនឹងកន្លែងសម្លាប់មនុស្សជើងឯកដែលពាក់ព័ន្ធ) រួមទាំងការបោសសម្អាតកម្មាភិបាលពីភូមិភាគឧត្តរថ្មី ភូមិភាគកណ្តាល (ឧត្តរចាស់) និងភូមិភាគបូព៌ាដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ប៉ុន្តែមិនរាប់បញ្ចូលការដ្ឋានព្រៃស ("ស-២១")[20]។ នៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញថា អង្គជំនុំជម្រះអាចនឹងយល់ព្រមពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ នៅក្នុងលក្ខណៈដែលត្រូវបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងស្នើឱ្យភាគីនានាដាក់សារណាស្តីពីបញ្ហានេះនៅកិច្ចប្រជុំរៀបចំសវនាការលើកក្រោយ[21] ដែលធ្វើឡើងនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២[22]។

---

[16] សំណើសុំពិចារណាឡើងវិញ កថាខណ្ឌ ៣, ៣២, ៣៤។ សូមមើល ផងដែរ សេចក្តីជូនដំណឹងអំពីសំណើសុំពិចារណាឡើងវិញ កថាខណ្ឌ ៤(ក)។

[17] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញ អំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ឯកសារ E124/7 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើការពិចារណាឡើងវិញ") ។

[18] សំណើសុំពង្រីកវិសាលភាព កថាខណ្ឌ ៤(ក), ៣៣(ក) *ដែលយោងទៅលើ*ដីកាដំណោះស្រាយ កថាខណ្ឌ ៦៩១, ៦៩៣-៦៩៧។

[19] សំណើសុំពង្រីកវិសាលភាព កថាខណ្ឌ ៤(ខ), ៣៣(ខ) *ដែលយោងទៅលើ*ដីកាដំណោះស្រាយ កថាខណ្ឌ ៦៩៨-៧១១។

[20] សំណើសុំពង្រីកវិសាលភាព កថាខណ្ឌ ៤(គ), ៣៣(គ) *ដែលយោងទៅលើ*ដីកាដំណោះស្រាយ កថាខណ្ឌ ១៩២-២០៤, ៤១៥-៤៧៥។

[21] អនុស្សរណៈពីចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ" ឯកសារ E218 ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ ("អនុស្សរណៈថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២") កថាខណ្ឌ ១៣-១៥។ សូមមើល ផងដែរ អនុស្សរណៈពីចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំពង្រីកវិសាលភាពនៃការ

7. នៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដែលត្រូវបានជំទាស់ បដិសេធសំណើសុំពង្រីកវិសាលភាព ទាក់ទិននឹងស្រុក១២ និងមន្ទីរ ស-២១[23] ប៉ុន្តែយល់ស្របទៅនឹងការដាក់បញ្ចូលទួលពោធិ៍ជ្រៃដែលបានស្នើឡើង "ដោយហេតុថា ការសម្លាប់ទាំងនេះជាហេតុការណ៍ដែលបានកើតឡើងភ្លាមៗ បន្ទាប់ពីមានការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ [...] ប៉ុន្តែការដាក់បញ្ចូលនេះគឺពុំសំដៅគ្របដណ្តប់លើការសម្លាប់នានាផ្សេងទៀតនៅទីតាំងនេះដែលបានកើតឡើងនៅចន្លោះឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៧ ឡើយ"[24]។

## ខ. បណ្តឹងសាទុក្ខភ្លាមៗ

8. នៅថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានដាក់បណ្តឹងសាទុក្ខភ្លាមៗ ដោយអះអាងថា បណ្តឹងសាទុក្ខនេះអាចទទួលយកបាន ហើយថា សេចក្តីសម្រេចដែលត្រូវបានជំទាស់មានកំហុសអង្គច្បាប់ កំហុសអង្គហេតុ និងកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង[25]។ ដូច្នេះ សហព្រះរាជអាជ្ញាស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូលកែប្រែសេចក្តីសម្រេចដែលត្រូវបានជំទាស់ ដើម្បីដាក់បញ្ចូលស្រុក១២ និងមន្ទីរសន្តិសុខ ស-២១ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១[26]។ ជនជាប់ចោទ នីមួយៗបានឆ្លើយតបប្រឆាំងទៅនឹងបណ្តឹងសាទុក្ខភ្លាមៗ[27] ចំណែកឯសហមេធាវីនាំមុខ

---

ជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163)" ឯកសារ E218.1 ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ ("ឧបសម្ព័ន្ធទៅនឹងអនុស្សរណៈថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២")។

[22] ប្រតិចារឹក(អង់គ្លេស) ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/114.1 ("កិច្ចប្រជុំរៀបចំសវនាការថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២")។

[23] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២។

[24] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣។

[25] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ២-៣, ១០-៨៦។

[26] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣, ៨៧។

[27] ចម្លើយតបរបស់លោក អៀង សារី ទៅនឹងបណ្តឹងសាទុក្ខបន្ទាន់របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E163/5/1/3 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("ចម្លើយតបរបស់ អៀង សារី")។ សារណាឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ភ្លាមៗរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E163/5/1/4 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("សារណាតបរបស់ នួន ជា")។ ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០១ ឯកសារ E163/5/1/9 ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("ចម្លើយតបរបស់ ខៀវ សំផន")។ សូមមើលផងដែរ សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តី ខៀវ សំផន សុំពន្យារពេលធ្វើការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះ

តំណាងដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយតបគាំទ្របណ្តឹងសាទុក្ខនេះ[28]។ សហព្រះរាជអាជ្ញាបានដាក់ការឆ្លើយតបដាច់ ដោយឡែកពីគ្នាទៅនឹងចម្លើយតបរបស់សហជនជាប់ចោទនីមួយៗ[29]។

## គ. ទឡ្ហីករណ៍ផ្ទាល់មាត់

9. វិធាន ១០៩(១) នៃវិធានផ្ទៃក្នុងចែងថា បណ្តឹងសាទុក្ខភ្លាមៗ អាចត្រូវបានសម្រេច ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ។ នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានស្នើឱ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈមួយ ទាក់ទិននឹងបណ្តឹងសាទុក្ខភ្លាមៗ[30] ដែលសំណើនេះត្រូវបានអង្គជំនុំជម្រះតុលាការកំពូលបដិសេធនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២[31]។ ដោយបានពិចារណាលើសារណាជាលាយលក្ខណ៍អក្សររបស់ភាគីនានា អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាមិនចាំបាច់ស្តាប់ទឡ្ហីករណ៍ផ្ទាល់មាត់នៅក្នុងករណីនេះឡើយ។

## ឃ. សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី

រាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ឯកសារ E163/5/1/2/1 ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១២។

[28] សារណាគាំទ្ររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E163/5/1/5 ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១២ (“សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី”)។

[29] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ អៀង សារី អំពីបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿងលេខ ០០២/០១ ឯកសារ E163/5/1/8 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (“ការឆ្លើយតបទៅ អៀង សារី”)។ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ នួន ជា ចំពោះបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿងលេខ ០០២/០១ ឯកសារ E163/5/1/10 ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ (“ការឆ្លើយតបទៅ នួន ជា”)។ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ ខៀវ សំផន ចំពោះបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿងលេខ ០០២/០១ ឯកសារ E163/5/1/11 ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២ (“ការឆ្លើយតបទៅ ខៀវ សំផន”)។

[30] សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យធ្វើសវនាការជាសាធារណៈ លើបណ្តឹងសាទុក្ខភ្លាមៗ ជំទាស់នឹងសេចក្តីសម្រេចពាក់ព័ន្ធនឹងវិសាលភាពនៃសវនាការក្នុងសំណុំរឿង ០០២/០១ ឬសំណើម្យ៉ាងទៀតសុំដាក់ចម្លើយតបរួមទៅនឹងចម្លើយតបទាំងពីររបស់មេធាវីការពារក្តី ឯកសារ E163/5/1/6 ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១២។

[31] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំបើកសវនាការលើបណ្តឹងសាទុក្ខ ពាក់ព័ន្ធនឹងវិសាលភាពនៃសវនាការសំណុំរឿង ០០២/០១ ឬស្នើសុំឱ្យដាក់ចម្លើយតបរួម ឯកសារ E163/5/1/12 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២។

10. វិធាន ៣៣ នៃវិធានផ្ទៃក្នុងចែងថា នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី បើយល់ថាចាំបាច់ដើម្បីវិនិច្ឆ័យទោសឱ្យបានត្រឹមត្រូវ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចអញ្ជើញ ឬអនុញ្ញាតឱ្យអង្គការ ឬបុគ្គលណាមួយដាក់ជូននូវសារណាជាលាយលក្ខណ៍អក្សររបស់ខ្លួន ពាក់ព័ន្ធនឹងបញ្ហាណាមួយបាន ដោយផ្តល់ឱ្យកាសដល់ភាគីទាំងអស់ដើម្បីឆ្លើយតប។ នៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១២ លោក Stan STARYGIN បានស្នើសុំការអនុញ្ញាតដាក់សារណាក្នុងនាមខ្លួនមិនមែនជាភាគីក្នុងរឿងក្តី ទាក់ទងនឹងបណ្តឹងសាទុក្ខភ្លាមៗនេះ[32]។ ដោយបានពិចារណាលើសារណាផ្សេងៗរបស់ភាគី ក៏ដូចជាភាពជាក់ស្តែងដែលថា ដោយសារពុំមានកាលៈទេសៈពិសេសណាមួយកើតឡើង បណ្តឹងសាទុក្ខមិនត្រូវតែសម្រេចឱ្យហួសថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឡើយ[33] ដូចនេះ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ឃើញថា ក្នុងករណីនេះ វាជាការចាំបាច់ត្រូវទទួលយកសារណារបស់អ្នកដែលពុំមែនជាភាគីមកពិចារណាក្នុងការជំនុំជម្រះលើបណ្តឹងសាទុក្ខនេះឡើយ។

11. អាស្រ័យហេតុនេះ អង្គជំនុំចម្រះតុលាការកំពូលសម្រេចបដិសេធលើសំណើនេះ។

## II. បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ

12. អនុលោមតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង មានតែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដូចខាងក្រោមនេះប៉ុណ្ណោះ ត្រូវបានបើកផ្លូវឱ្យប្តឹងសាទុក្ខភ្លាមៗ៖ (ក) សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី (ខ) សេចក្តីសម្រេចអំពីការឃុំខ្លួន និងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការអនុលោមតាមវិធាន ៨២ (គ) សេចក្តីសម្រេចអំពីវិធានការការពារតាមវិធាន ២៩(៤)(គ) នៃវិធានផ្ទៃក្នុង និង (ឃ) សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់

---

[32] អ៊ីម៉ែលរបស់ Dr. Stan STARYGAN ចំណងជើងថា "សំណើសុំការអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី" ផ្ញើ នៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៣ វេលាម៉ោង ១៤ និង ២៦ នាទី។

[33] សូមមើល វិធាន ១០៨ (៤ស្ទួន)(ខ)("អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ (...) ប្រឆាំងនឹងសេចក្តីសម្រេចទាក់ទងនឹងវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុងក្នុងរយៈពេលបីខែ បន្ទាប់ពីទទួលបានសំណុំរឿង និងឯកសារនៃសេចក្តីសម្រេច និងបណ្តឹងសាទុក្ខភ្លាមៗនីមួយៗ។ ប៉ុន្តែ ក្នុងករណីពិសេស អង្គជំនុំជម្រះតុលាការកំពូល អាចពន្យារពេលនេះមួយខែបន្ថែមទៀត។ ប្រសិនបើសេចក្តីសម្រេចនេះ មិនត្រូវបានចេញក្នុងរយៈពេលកំណត់នោះទេ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវចាត់ទុកជាបានការ")។ ក្នុងរឿងក្តីបច្ចុប្បន្ននេះ សំណុំរឿងរួមជាមួយនឹងសេចក្តីសម្រេចដែលរងការជំទាស់ និងបណ្តឹងសាទុក្ខភ្លាម ត្រូវបានជូនដំណឹង និងទទួលនៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២។

អង្គជំនុំជម្រះតាមវិធាន៣៥(៦) នៃវិធានផ្ទៃក្នុង។ សេចក្តីសម្រេចផ្សេងទៀត អាចប្តឹងសាទុក្ខបានតែក្នុងករណីដែលបានធ្វើឡើងស្របពេលជាមួយបណ្តឹងសាទុក្ខ ពីសាលក្រមលើអង្គសេចក្តី។

13. អនុលោមតាមវិធាន ១០៤(១) និង ១០៥(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូល ត្រូវសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម៖ (ក) កំហុសលើអង្គច្បាប់ដែលនាំឱ្យមោឃៈសេចក្តីសម្រេច (ខ) កំហុសនៃអង្គហេតុដែលនាំឱ្យសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌ ឬ (គ) ការភ័ន្តច្រឡំ ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។

## III. ភាពអាចទទួលយកបាន

14. សហព្រះរាជអាជ្ញាសន្និដ្ឋានថា សេចក្តីសម្រេចដែលត្រូវបានជំទាស់ អាចត្រូវបានប្តឹងសាទុក្ខភ្លាមៗ អនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ពីព្រោះតែសេចក្តីសម្រេចនេះ មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីទាក់ទងនឹងស្រុក១២ និងមន្ទីរ ស-២១[34]។ ជាពិសេស សហព្រះរាជអាជ្ញាជំទាស់ថា វិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ចែងអំពីការពិនិត្យបណ្តឹងសាទុក្ខឡើងវិញ នៅក្នុងកាលៈទេសៈដែលលទ្ធភាពនៃកិច្ចដំណើរការនីតិវិធីនាពេលអនាគត គឺឋិតនៅឆ្ងាយ មិនអាចមើលឃើញបាន[35] និងបណ្តឹងសាទុក្ខភ្លាមៗ ត្រូវបានដាក់នៅក្នុងរយៈពេលកំណត់ដែលអាចដាក់បាន[36]។

15. សហជនជាប់ចោទនីមួយៗ បានដាក់ចម្លើយតបថា បណ្តឹងសាទុក្ខភ្លាមៗ មិនអាចទទួលយកបានផ្អែកតាមវិធានផ្ទៃក្នុង អាស្រ័យហេតុនេះ បណ្តឹងសាទុក្ខនេះ គួរត្រូវបានបដិសេធចោល[37]។ អៀង សារី និង ខៀវ សំផន ក៏បានជំទាស់ថា បណ្តឹងសាទុក្ខភ្លាមៗ ត្រូវតែបដិសេធចោល ដោយសារតែបណ្តឹងនេះ

---

[34] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣, ១០-១៩។ *សូមមើលផងដែរ* បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ២, ២០។ សារណាតបទៅនឹង អៀង សារី កថាខណ្ឌ ១៩។ សារណាតបទៅនឹង នួន ជា កថាខណ្ឌ ២៧។ សារណាតបទៅនឹង ខៀវ សំផន កថាខណ្ឌ ១១។

[35] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣, ១១-១៩។ *សូមមើលផងដែរ* សារណាតបទៅនឹង អៀង សារី កថាខណ្ឌ ១០-១៨។ សារណាតបទៅនឹង នួន ជា កថាខណ្ឌ ៣-៤។

[36] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ២០។ *សូមមើលផងដែរ* សារណាតបទៅនឹង អៀង សារី កថាខណ្ឌ ៣-៩។ សារណាតបទៅនឹង ខៀវ សំផន កថាខណ្ឌ ៣។

[37] ចម្លើយតបរបស់ អៀង សារី ទំព័រ១ កថាខណ្ឌ ៣០-៤៩។ ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ១, ៣-៥, ៣៦។ ចម្លើយតបទៅនឹង ខៀវ សំផន កថាខណ្ឌ ៨-២០, ៥៦។

ដាក់មិនត្រឹមត្រូវតាមពេលវេលាកំណត់[38]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនបាន លើកឡើងច្បាស់លាស់ទាក់ទិននឹងភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខនោះទេ។

## ក. ភាពទាន់ពេលវេលា

16. សហព្រះរាជអាជ្ញាលើកឡើងថា ខ្លួនបានទប់មិនប្តឹងសាទុក្ខទៅនឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី រហូតទាល់តែវិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានកំណត់ច្បាស់ចុងក្រោយ ដែលក្រោយពីការចេញសេចក្តីសម្រេចដែលត្រូវបានជំទាស់តែប៉ុណ្ណោះ[39]។ លោក អៀង សារី ឆ្លើយតបថា បណ្តឹងសាទុក្ខភ្លាមៗនេះ បានដាក់ហួសរយៈពេលកំណត់ ដោយសារតែការខកខានមិនបានប្តឹងសាទុក្ខលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ឬសេចក្តីសម្រេចលើសំណើសុំឱ្យ ពិចារណាឡើងវិញ[40]។ ខៀវ សំផន ឆ្លើយតបស្រដៀងគ្នា ដោយបន្ថែមនូវទឡ្ហីករណ៍ថា ដោយពិចារណាទៅលើដំណាក់កាលវិវត្តន៍ទៅមុខនៃកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០១ សេចក្តីសម្រេចអនុញ្ញាតឱ្យមានបណ្តឹងសាទុក្ខភ្លាមៗនៅក្នុងរយៈពេលកំណត់ ដូចមានចែងផ្អែកតាមវិធាន ១០៨(៤ស្ទួន)(ខ) នៃវិធានផ្ទៃក្នុង គឺ "រារាំង"[41] និង "បង្កនូវផលវិបាកធ្ងន់ធ្ងរ"[42] ដល់ការជំនុំជម្រះក្តីទាពេលបច្ចុប្បន្ន[43]។ ត្រង់ចំណុចនេះ សហព្រះរាជអាជ្ញាឆ្លើយតបវិញថា ការសំអាងរបស់ ខៀវ សំផន លើវិធាន ១០៨(៤ស្ទួន)(ខ) នៃវិធានផ្ទៃក្នុងដើម្បីបដិសេធចោលបណ្តឹងសាទុក្ខភ្លាមៗ គឺមិនត្រឹមត្រូវ និងភ័ន្តច្រឡំ ហើយក៏មិនមានមូលដ្ឋានដើម្បីជំទាស់ថា ការដាក់បញ្ចូលបន្ថែមនូវមន្ទីរ ស-២១ និង ស្រុក១២ នៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ បានរំលោភលើសិទ្ធិរបស់សហជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌នោះទេ[44]។

17. ជាបឋម អង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលសញ្ញាណណាមួយ ដែលចែងអំពីរយៈពេលកំណត់សម្រាប់បដិសេធចោលបណ្តឹងសាទុក្ខភ្លាមៗ ប្រសិនបើមានផលប៉ះពាល់ណាមួយលើភាពទាន់ពេលវេលា ភាពអាចទទួលយកបាន ឬអង្គសេចក្តីនៃបណ្តឹងសាទុក្ខភ្លាមៗនោះ។ ចំពោះទឡ្ហីករណ៍ដែលលើក

---

[38] ចម្លើយតបរបស់ អៀង សារី ទំព័រ១ កថាខណ្ឌ ២១-២៩, ៥៩។ ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ២១-២៤។

[39] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ២០។ *សូមមើលផងដែរ*ចម្លើយតបទៅនឹង អៀង សារី កថាខណ្ឌ ២-៩។

[40] ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ២១-២៩។ *សូមមើលផងដែរ* ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ៦, ៩, ១២។

[41] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ២២។

[42] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ២៤។

[43] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ២១-២៤។

[44] ចម្លើយតបទៅនឹង ខៀវ សំផន កថាខណ្ឌ ៤-៧។

ឡើងថា សហព្រះរាជអាជ្ញាបានដាក់មិនទាន់ពេលវេលាកំណត់ដោយសារតែកង្វះវិរិយភាព អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សេចក្តីសម្រេចដែលរងការជំទាស់នេះ ជាប់ទាក់ទងនឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងបង្កើតបានជាផ្នែកចុងក្រោយនៅក្នុងដំណើរការសេចក្តីសម្រេចអស់រយៈពេលមួយឆ្នាំ ដែលបានចេញសេចក្តីប្រកាសជាច្រើនលើកលើបញ្ហាដដែល នៅក្នុងកាលៈទេសៈផ្នែកច្បាប់ និងអង្គហេតុដដែល[45]។ បន្ថែមពីលើនេះ ការពិនិត្យមើលប្រវត្តិនីតិវិធីបង្ហាញថា ចន្លោះពេលវេលានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះសាលាដំបូងនៅតែមិនទាន់កំណត់វិសាលភាពសំណុំរឿង ០០២/០១ ឲ្យប្រាកដប្រជា និងបើកឲ្យមានការកែប្រែ ដោយមិនមានកំណត់លក្ខខណ្ឌវិនិច្ឆ័យ ដែលអាចជះឥទ្ធិពលចំពោះការកែប្រែណាមួយនោះទេ[46]។ ជាការពិត អង្គ

---

[45] *សូមមើលខាងលើ*កថាខណ្ឌ ៣៧ និង ៤៩។

[46] *សូមមើល ឧទា.* ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៦ (“អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចដាក់បញ្ចូលបន្ថែមនូវផ្នែកផ្សេងទៀតនៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២”)។ សេចក្តីសម្រេចលើសំណើសុំឲ្យពិចារណាឡើងវិញ កថាខណ្ឌ១២ (“នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងមិនបានបដិសេធចោលនូវលទ្ធភាពនៃការដាក់បញ្ចូលការចោទប្រកាន់ ឬបទចោទបន្ថែមនៅក្នុងការជំនុំជម្រះដំណាក់កាលដំបូងក្នុងសំណុំរឿង ០០២ ឡើង នៅពេលដែលកាលៈទេសៈអនុញ្ញាត។ ទោះបីជាអង្គជំនុំជម្រះកត់សម្គាល់នូវការចង្អុលបង្ហាញរបស់សហព្រះរាជអាជ្ញានៅក្នុងសំណើសុំ [ឲ្យពិចារណាឡើងវិញ] របស់ខ្លួនអំពីបញ្ហាបន្ថែមដែលអាចមានសម្រាប់ដាក់បញ្ចូលនៅក្នុងការជំនុំជម្រះដំណាក់កាលដំបូង ហើយអង្គជំនុំជម្រះត្រូវបានណែនាំដោយការយល់ឃើញរបស់សហព្រះរាជអាជ្ញាថា ជាការចោទប្រកាន់ជាអាទិភាពសម្រាប់ធ្វើការពិចារណាក្នុងអំឡុងដំណាក់កាលនៃការជំនុំជម្រះក្រោយៗទៀតក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ពុំមានមូលដ្ឋានក្នុងការពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួននៅដំណាក់កាលនេះឡើយ” (ឯកសារយោងផ្ទៃក្នុងត្រូវបានលុបចោល))។ អនុស្សរណៈរបស់ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានកម្មវត្ថុ “សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១” ឯកសារ E172 ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ និងបានដាក់កាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ ទំព័រ ៤ (“អង្គជំនុំជម្រះបានទទួលនូវ [សំណើសុំពន្លាតវិសាលភាព]។ ដូចដែលអង្គជំនុំជម្រះបានបញ្ជាក់នៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធី និងនៅក្នុងសេចក្តីសម្រេចពាក់ព័ន្ធនានាកាលពីពេលមុននោះ អង្គជំនុំជម្រះអាចពន្លាតវិសាលភាពអង្គហេតុសម្រាប់សវនាការសំណុំរឿង ០០២/០១ ទៅតាមគំនិតផ្តួចផ្តើម និងឆន្ទានុសិទ្ធិរបស់ខ្លួន។ ប្រសិនបើអង្គជំនុំជម្រះសម្រេចពន្លាតវិសាលភាពនៃសំណុំរឿង ០០២/០១ នោះ អង្គជំនុំជម្រះនឹងជូនដំណឹងដល់ភាគីក្នុងពេលវេលាមួយសមស្របជាមុន”)។ អនុស្សរណៈចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០១២ កថាខណ្ឌ ១៣ (“សហព្រះរាជអាជ្ញា បានជំរុញម្តងហើយម្តងទៀតឲ្យមានការលើកឡើងអំពីការពង្រីកវិសាលភាពនៃការចោទប្រកាន់នានានៅក្នុងសំណុំរឿង ០០២/០១ [...]។ ទោះបីជាកិច្ចខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះសាលាដំបូងមកទល់នឹងពេលនេះ គឺជាការយកចិត្តទុកដាក់ដើម្បីធានាឲ្យការជំនុំជម្រះកាន់តែមានប្រសិទ្ធភាពក៏ដោយ អង្គជំនុំជម្រះក៏បានលះបង់ពេលវេលា និងធនធានយ៉ាងធំធេងដើម្បីធ្វើការវាយតម្លៃលើផលប៉ះពាល់នៃការយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការស្នើសុំពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ [សំណើសុំពន្លាតវិសាលភាព]។ ឧបសម្ព័ន្ធដែល

ជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងមិនបានបង្ហាញការកំណត់ច្បាស់ចុងក្រោយនៃសេចក្ដីសម្រេចដែលរងការជំទាស់នោះ ស្ដីអំពីវិសាលភាពនៃសំណុំរឿង ០០២/០១ រហូតមកទល់ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ដែលមានរយៈពេល ១១ ថ្ងៃ ក្រោយពីការចេញសេចក្ដីសម្រេចដែលត្រូវបានជំទាស់ នៅពេលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងយ៉ាងច្បាស់ជាលើកដំបូងថា "នឹងពុំពិចារណាអំពីការពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ឲ្យលើសពីនេះទៀតឡើយ"[47]។ យោងតាមកាលៈទេសៈទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថាដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្ដីសម្រេចដែលរងការជំទាស់ រួមជាមួយនឹងអនុស្សរណៈដែលជាប់ពាក់ព័ន្ធទាំងអស់ គឺជាសេចក្ដីសម្រេចមួយយ៉ាងទូលំទូលាយដែលជាប់ទាក់ទងទៅនឹង ការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០១។ ហេតុដូច្នេះអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការខកខានធ្វើបណ្ដឹងសាទុក្ខលើដីកាបំបែកកិច្ចដំណើរការនីតិវិធី ឬសេចក្ដីសម្រេចលើសំណើសុំឲ្យពិចារណាឡើងវិញ ពុំបានប៉ះពាល់ដល់សិទ្ធិដើម្បីប្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចដែលត្រូវបានជំទាស់នោះទេ។

18. វិធាន ១០៧(១) នៃវិធានផ្ទៃក្នុង ចែងថា បណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចដែលបើកឲ្យមានបណ្ដឹងសាទុក្ខភ្លាមៗ ផ្អែកតាមវិធាន ១០៤(៤)(ក) និង១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង ត្រូវតែធ្វើឡើងក្នុង

---

បានភ្ជាប់ជាមួយនេះ បង្ហាញអំពីការពង្រីកវិសាលភាពខ្លះៗ ដែលអង្គជំនុំជម្រះមានបំណងពិចារណាទាក់ទងទៅនឹង [ស្រុង១២ និងទួលពោធិជ្រៃ]")។ ឧបសម្ព័ន្ធភ្ជាប់នឹងអនុស្សរណៈចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ១ ("អង្គជំនុំជម្រះសាលាដំបូង បានគូសបញ្ជាក់ម្ដងហើយម្ដងទៀតថា ក្នុងការអនុវត្តឆន្ទានុសិទ្ធិលើការរៀបចំសវនាការរបស់ខ្លួន ការពង្រីកវិសាលភាពនៃការជំនុំជម្រះអាចត្រូវបានពិចារណាទៅតាមភាពជាក់ស្ដែង ដែលនៅពេលនោះ សំណូមពររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងប្រធានបទបន្ថែមដែលអាចដាក់បញ្ចូលនៅក្នុងសវនាការដំណាក់កាលដំបូង នឹងត្រូវលើកយកមកពិចារណា"។ (សម្រង់ផ្ទៃក្នុងត្រូវបានលុបចោល) កថាខណ្ឌ៥ ("ដើម្បីត្រួសត្រាយការពិភាក្សាអំពីចំណុចបន្ថែមនៅឯកិច្ចប្រជុំរៀបចំសវនាការ ពាក់ព័ន្ធនឹងការស្នើសុំដើម្បីពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងផ្ដល់សេចក្ដីវិភាគដូចខាងក្រោមអំពីចំណុចបន្ថែមដែលសហព្រះរាជអាជ្ញាបានស្នើសុំ និងគូសបញ្ជាក់អំពីចំណុចនានា ដែលអង្គជំនុំជម្រះអាចត្រៀមរៀបចំដើម្បីពិចារណាអំពីការដាក់បញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១")។

[47] អនុស្សរណៈរបស់ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានកម្មវត្ថុ "សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភ័ស្ដុតាងគាំទ្រ (ឯកសារ E223)" ឯកសារ E223/2 ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ កថាខណ្ឌ ៣។

រយៈពេល ៣០ ថ្ងៃ ចាប់ពីថ្ងៃប្រកាសសេចក្តីសម្រេច ឬពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនោះ។ សេចក្តីសម្រេចដែលត្រូវបានជំទាស់ ត្រូវបានដាក់កាលពីថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ និងបណ្តឹងសាទុក្ខភ្លាមៗ ត្រូវដាក់នៅ ៣០ ថ្ងៃ ក្រោយពីថ្ងៃចេញសេចក្តីសម្រេច ដែលចំថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២។

19. ហេតុដូច្នេះ បណ្តឹងសាទុក្ខភ្លាមៗ ត្រូវបានដាក់អនុលោមតាមវិធាន ១០៧(១) នៃវិធានផ្ទៃក្នុង។

## ខ. វិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង

20. សហព្រះរាជអាជ្ញាលើកឡើងថា សញ្ញាណនៃ "អានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី" ដែលមានចែងនៅក្នុងវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង "ត្រូវតែបកស្រាយឲ្យបានសមហេតុផល ដោយបញ្ចូលបញ្ហាទាំងឡាយដែលបានរារាំងមកដល់ពេលនេះ ទៅជាមានភាពមិនច្បាស់លាស់ នៅពេលអនាគតដែលមានឱកាសបន្តិចបន្តួចសម្រាប់សវនាការ"[48]។ សហព្រះរាជអាជ្ញាតវ៉ាថា កាលៈទេសៈនៃរឿងក្តីបច្ចុប្បន្ន ស្ថិតនៅក្នុងវិសាលភាពនៃវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ដូចដែលបានបកស្រាយ ពីព្រោះតែលទ្ធភាពនៃកិច្ចដំណើរការនីតិវិធី នៅពេលអនាគតក្នុងសំណុំរឿង ០០២ គឺឋិតនៅឆ្ងាយមិនអាចមើលឃើញបាន ដោយសារតែអាយុកាន់តែច្រើន និងសេចក្តីព្រួយបារម្ភទាក់ទងនឹងសុខភាពរបស់សហជនជាប់ចោទ និងពីព្រោះតែបញ្ហាជាច្រើននៅតែមិនទាន់ត្រូវបានដោះស្រាយ ទាក់ទិននឹងតាមរបៀបណា និងនៅពេលណាដែលការជំនុំជម្រះក្តីដំណាក់កាលទីពីរ ("សំណុំរឿងលេខ ០០២/០២") អាចដំណើរការទៅមុខ[49]។ សហព្រះរាជអាជ្ញាជំទាស់ថា សេចក្តីសម្រេចដែលត្រូវបានជំទាស់នេះ រារាំងដល់ការវិនិច្ឆ័យសេចក្តីលើបទចោទនានាពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មដែលគេមិនបានដាក់បញ្ចូល ដែលមានអនុភាពបញ្ចប់កិច្ចដំណើរ

---

[48] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ១១។ *សូមមើលផងដែរ* សារណាតបទៅនឹង អៀង សារី កថាខណ្ឌ ១១-១២។

[49] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ១៥-១៨។ *សូមមើលផងដែរ* សារណាតបទៅនឹង អៀង សារី កថាខណ្ឌ ១៤-១៥។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏បានអះអាងប្រហាក់ប្រហែលគ្នាដែលថា តាម"លទ្ធភាពជាក់ស្តែងក្នុងបច្ចុប្បន្ន ដែលថាការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ គឺជាការជំនុំជម្រះចុងក្រោយបង្អស់របស់ អ.វ.ត.ក"។ សូមមើល សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦។ សូមមើល ផងដែរ ការជូនដំណឹងអំពីសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំធ្វើការពិចារណាឡើងវិញ កថាខណ្ឌ ៦(គ) ("សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដឹងថា ការជំនុំជម្រះលើកទីមួយនេះ អាចក្លាយជាការជំនុំជម្រះតែមួយគត់")។ សំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំការពិចារណាឡើងវិញ កថាខណ្ឌ ១ ("ដោយដឹងថា អាយុរបស់ជនជាប់ចោទកាន់តែចាស់ទៅ និងបញ្ហាកើតមានជាអចិន្ត្រៃយ៍របស់តុលាការលើបញ្ហាហិរញ្ញវត្ថុ យើងជឿជាក់ថា ការជំនុំជម្រះនេះគឺចុងក្រោយបង្អស់។ ប្រសិនបើដូច្នេះមែននោះ ដីកាបំបែកសំណុំរឿង គឺជាក់ស្តែង ជាការមិនបន្តកិច្ចដំណើរការនីតិវិធីសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានចំនួនដ៏សន្ធឹកសន្ធាប់"), ២៧។

ការនីតិវិធី[50]។ សហព្រះរាជអាជ្ញាបញ្ជាក់បន្ថែមថា សិទ្ធិរបស់ពួកគេដើម្បីប្តឹងឧទ្ធរណ៍ចំពោះកំហុសឆ្គងនានាដែលបានចោទប្រកាន់ មិនអាចត្រូវបានធានានោះទេ ប្រសិនបើតម្រូវឲ្យសហព្រះរាជអាជ្ញារង់ចាំរហូតដល់ចេញសាលក្រមស្តាពរលើអង្គសេចក្តីនោះទេ[51] ដោយលើកទឡ្ហីករណ៍ថា "ពុំមានយន្តការតាមផ្លូវច្បាប់ណាមួយ និងមិនអាចដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មដែលបានច្រានចោលក្នុងបណ្តឹងសាទុក្ខ"[52]។ បន្ថែមពីលើនេះ សហព្រះរាជអាជ្ញាលើកឡើងអំពីវិធាន ២១ នៃវិធានផ្ទៃក្នុងដើម្បីលើកទឡ្ហីករណ៍ដែលអនុញ្ញាតឲ្យបណ្តឹងសាទុក្ខភ្លាមៗ ធានាអំពីសិទ្ធិនៃជនរងគ្រោះដោយមិនមានផលប៉ះពាល់ទៅលើសិទ្ធិរបស់ភាគីនានានោះទេ[53]។

21. សហជនជាប់ចោទ ឆ្លើយតបថា សេចក្តីសម្រេចដែលត្រូវបានជំទាស់ មិនបានបញ្ចប់កិច្ចដំណើរការនីតិវិធីណាមួយទេ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងលើកឡើងយ៉ាងច្បាស់ថា គ្មានបទចោទនៅក្នុងដីការបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានបង្អាក់នោះទេ ហើយការជំនុំជម្រះដំណាក់កាលទីពីរ នឹងចាប់ផ្តើមក្នុងពេលឆាប់ៗ បន្ទាប់ពីបញ្ចប់ការសួរដេញដោលនូវភ័ស្តុតាងក្នុងសំណុំរឿង០០២/០១[54]។ សហជនជាប់ចោទ ជំទាស់ថា អំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលលើកឡើងថា ការជំនុំជម្រះនាពេលអនាគតគឺឋិតនៅឆ្ងាយមិនអាចមើលឃើញបាន អំណះអំណាងនេះគឺគ្រាន់តែប៉ាន់ស្មាន ហើយអាយុ និងសុខភាពរបស់សហជនជាប់ចោទ ព្រមទាំងបញ្ហាជាក់ស្តែងនានាទាក់ទិននឹងការចាប់ផ្តើមសំណុំរឿង០០២/០២ មិនពាក់ព័ន្ធនឹងការបញ្ចប់នៃកិច្ចដំណើរការនីតិវិធីនោះទេ ប៉ុន្តែពាក់ព័ន្ធតែការពន្យារពេលដែលអាចមានតែប៉ុណ្ណោះ[55]។ អៀង សារី បន្ថែមថា ជម្រើសតែមួយរបស់សហព្រះរាជអាជ្ញា គឺប្តឹងសាទុក្ខក្រោយពីការចេញនូវសាលក្រមស្តាពរ[56] ឧបាស្រ័យដែលគាត់បានអំណះអំណាង នឹងអាចការពារបានគ្រប់គ្រាន់ដល់

---

[50] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ១២-១៣។ *សូមមើលផងដែរ* សារណាតបទៅនឹង អៀង សារី កថាខណ្ឌ ១៣។

[51] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ១២-១៤។ *សូមមើលផងដែរ* សារណាតបទៅនឹង អៀង សារី កថាខណ្ឌ ១៥។

[52] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ១៣។ *សូមមើល*បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ១៤។

[53] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ១៩។

[54] ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ៣៣, ៣៧, ៤៣។ ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៣-៤។ ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ៨-៩, ១១។

[55] ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ៣៦, ៣៨-៣៩។ ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៥។ ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១៤-១៧ និង ៣៤។

[56] ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ៣៩-៤១។ *សូមមើលផងដែរ* ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១០-១២, ១៨-២០។

ផលប្រយោជន៍របស់សហព្រះរាជអាជ្ញា និងជនរងគ្រោះ[57] ចំណែកឯការទទួលយក និងការអនុញ្ញាតឱ្យមានបណ្តឹងសាទុក្ខភ្លាមៗ នឹងធ្វើឱ្យគាត់ប៉ះពាល់ដល់ផលប្រយោជន៍[58]។

22. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា សិទ្ធិប្តឹងសាទុក្ខដែលមានចែងនៅក្នុងវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ធានាថា មធ្យោបាយនៃបណ្តឹងសាទុក្ខធ្វើឡើង នៅពេលដែលកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់ដោយមិនទាន់ចេញសាលក្រម ដូច្នេះទើបភាគីមិនមានឱកាសដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម[59]។ អង្គជំនុំជម្រះបានបកស្រាយវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ដើម្បីរួមបញ្ចូលសេចក្តីសម្រេចនានាក្នុងការផ្អាកកិច្ចដំណើរការនីតិវិធី ដែលមិនបានសន្យាច្បាស់លាស់ណាមួយនៃការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីឡើងវិញ និងរារាំងដល់ការចេញសាលក្រមលើអង្គសេចក្តី[60]។ នៅក្នុងបរិបទ អ.វ.ត.ក ដែលមានតែអង្គជំនុំជម្រះសាលាដំបូងតែមួយគត់ ដោយមានការជំនុំជម្រះតែមួយនៅក្នុងបញ្ជីរឿងក្តីរបស់ខ្លួន ការបំបែកសំណុំរឿង ០០២ ឱ្យទៅជាការជំនុំជម្រះតូចៗ បង្កើតជាស្ថានការណ៍ដែលមិនអាចជៀសផុតដែលថា កិច្ចដំណើរការនីតិវិធីទាក់ទិននឹងបទចោទ ដែលឋិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ គឺមានអនុភាពផ្អាកសិន។ សេចក្តីសន្និដ្ឋានបែបនេះ ពុំត្រូវបានជំទាស់ឡើយ ហើយ ក៏ពុំមានសេចក្តីអះអាងបញ្ជាក់ណាមួយដែលថា ការផ្អាកកិច្ចដំណើរការនីតិវិធីដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ស្តីពីបញ្ហា ស ២១ និង ស្រុក ១២ នោះ ថាជាការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ឡើយ។ ផ្ទុយទៅវិញ បញ្ហានេះ គឺថាតើ មានលទ្ធភាពគ្រប់គ្រាន់ដែលអាចបន្តឡើងវិញនូវកិច្ចដំណើរការនីតិវិធីទាក់ទងនឹង បទចោទដែលត្រូវបានដកចេញពីវិសាលភាពនៃសំណុំរឿង ០០២/០១ ដើម្បីអាចឈានដល់ការចេញសាលក្រមមួយតាមពេលសមស្រប។

---

[57] ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ៤១-៤៣។ *សូមមើលផងដែរ* ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១៧-១៨។

[58] ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ៤៤-៤៥។

[59] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឯកសារ E95/8/1/4 ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ៩។

[60] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ឯកសារ E138/1/7 ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (“សេចក្តីសម្រេចលើការដោះលែង អៀង ធីរិទ្ធ”) កថាខណ្ឌ ១៥។

23. អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា "ការចោទប្រកាន់ ឬបទចោទនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមានទំនាក់ទំនងបន្តបន្ទាប់គ្នានៅក្នុងដីកាបំបែកសំណុំរឿងនោះ"[61] ហើយអង្គជំនុំជម្រះ មាន "ចេតនាបញ្ចប់សវនាការដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ ក្នុងឆ្នាំ២០១៣ និងចាប់ផ្តើមសំណុំរឿង ០០២/០២ ភ្លាមៗ ក្រោយការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១"[62]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងមិនបានបញ្ជាក់ថាតើមន្ទីរ ស-២១ និងស្រុក១២ ជាផ្នែកមួយនៅក្នុងសំណុំរឿង ០០២/០២ ដែរឬយ៉ាងណានោះទេ។ ជាការពិត អង្គជំនុំជម្រះសាលាដំបូង មិនបានផ្តល់ព័ត៌មានច្បាស់ ឬជាក់លាក់ណាមួយ ត្រង់ចំណុចនៃចំនួន ឬវិសាលភាពនៃការជំនុំជម្រះក្តីដែលត្រូវមាន បន្ទាប់ពីសំណុំរឿង ០០២/០១ នោះទេ[63]។ ទោះបីជាមានផ្តល់ព័ត៌មានបែបនោះក៏ដោយ បញ្ហាចោទនៅតែបន្តមាន ត្រង់ចំណុចថាតើការចេញសាលក្រមលើអង្គសេចក្តីទាក់ទិននឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់មន្ទីរ ស-២១ និងស្រុក ១២ អាចមានអនុភាពទប់ស្កាត់ដោយសារតែការលើកទៅជំនុំជម្រះនាពេលអនាគត។

24. ផ្អែកតាមសារណារបស់ភាគីនានា សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយទៅនឹងសំណួរក្នុងលក្ខណៈវិជ្ជមាន ខណៈពេលដែលសហជនជាប់ចោទជំទាស់ថាចម្លើយណាមួយទៅនឹងសំណួរនេះ គឺគ្រាន់តែជាការប៉ាន់ស្មានប៉ុណ្ណោះ។ ចំពោះទស្សនៈរបស់អង្គជំនុំជម្រះតុលាការកំពូល ទោះបីជាវិធានការនៃការប៉ាន់ស្មាន តែងតែពាក់ព័ន្ធនឹងដំណើរការនៃការធ្វើការប៉ាន់ស្មាន ប៉ុន្តែការពិតមួយចំនួនដែលមិនអាចជៀសរួចនៅក្នុងសំណុំរឿងបច្ចុប្បន្ន ដែលនាំឲ្យមានការវាស់ស្ទង់នៃលទ្ធភាពដើម្បីអាចឲ្យធ្វើការសន្និដ្ឋានបែបនោះ។ ការពិតទាំងនោះរួមមាន៖ អាយុកាន់តែច្រើន និងសុខភាពដុនដាបរបស់សហជនជាប់ចោទ[64] ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្តល់ផែនការច្បាស់

---

[61] សេចក្តីសម្រេចលើសំណើសុំឲ្យពិចារណាឡើងវិញ កថាខណ្ឌ៩។

[62] អនុស្សរណៈចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ១។

[63] ទោះបីជាមានការបង្ហាញរបស់ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធីដែលបានលើកឡើងថា "ព័ត៌មានបន្ថែមទាក់ទិននឹងសំណុំរឿងបន្តបន្ទាប់ដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ នឹងត្រូវជូនដំណឹងដល់ភាគី និងសាធារណជនក្នុងពេលសមស្រប"។ *សូមមើល* ដីកាបំបែកកិច្ចដំណើរការនីតិវិធី ទំព័រ ៤។

[64] នៅពេលសរសេរ អៀង សារី អាយុ ៨៧ ឆ្នាំ (កើតនៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩២៥), នួន ជា អាយុ ៨៦ ឆ្នាំ(កើតនៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩២៦) ហើយ ខៀវ សំផន អាយុ ៨១ ឆ្នាំ (កើតនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៨៣)។ *សូមមើល* ដីកាដំណោះស្រាយ ទំព័រ ៧។ ទាក់ទងនឹងបញ្ហាសុខភាពរបស់ពួកគេដែលចេះតែដុនដាប់ទៅ *សូមមើល* អនុស្សរណៈរបស់ចៅក្រម និល ណុន ជាប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "ការចាត់តាំងឡើងវិញនូវអ្នកជំនាញដើម្បីពិនិត្យសុខ

លាស់ ឬផ្តល់ព័ត៌មានណាមួយមកទល់ពេលនេះ ទាក់ទិននឹងសំណុំរឿងបន្តបន្ទាប់ដែលត្រូវជំនុំជម្រះនៅក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២[65] ការលំបាកដែលអង្គជំនុំជម្រះបានលើកឡើងថ្មីៗនេះនៅក្នុងកិច្ចប្រជុំអំពីតម្រូវការទំហំការងារ[66] និងការពិតដែលថា នៅក្នុងបរិបទអ.វ.ត.ក សាលក្រមលើអង្គសេចក្តីមិនមែនជាសេចក្តីសម្រេចស្ថាពរនោះទេ រហូតទាល់តែសេចក្តីសម្រេចនេះ ឆ្លងកាត់ដំណាក់កាលនៃការប្តឹងសាទុក្ខសិន[67]។ កត្តាទាំងនេះរួមបញ្ចូលគ្នា បានផ្តល់នូវសំអាងហេតុសមហេតុផលសម្រាប់ទុទិដ្ឋិនិយមរបស់សហព្រះរាជអាជ្ញាអំពីអនាគតរបស់សំណុំរឿង ០០២។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា មេធាវីការពារក្តី នួន ជា បានលើកឡើងស្រដៀងគ្នានេះដែរ កាលពីពេលមុនអំពីបញ្ហានេះ[68]។

---

ភាព និងកាយសម្បទារបស់ អៀង សារី និង នួន ជា នៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៣", ឯកសារលេខ E256, ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ២ ("[នួន ជា និង អៀង សារី] ទាំងពីរនាក់ មានជំងឺរ៉ាំរ៉ៃប្រចាំកាយជាច្រើន ហើយតាមដានកិច្ចដំណើរការនីតិវិធីជាប្រចាំពីបន្ទប់ឃុំខ្លួនក្រោមសវនាការ")។ ប្រតិចារិក ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣ ឯកសារលេខ E1/157.1, ទំព័រ ២ ដល់ ៣ (រកឃើញថា លក្ខខណ្ឌសុខភាពរបស់ អៀង សារី និង នួន ជា មិនអាចធ្វើឱ្យគាត់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការបានឡើយ)។ អនុស្សរណៈរបស់ចៅក្រម និល ណុន ជាប្រធានអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ការផ្អាកកិច្ចដំណើរការនីតិវិធី", ឯកសារលេខ E258, ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៣ (ការផ្អាកកិច្ចដំណើរការនីតិវិធីដោយសារនាំ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរពេទ្យ)។ ប្រតិចារិក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ឯកសារលេខ E1/161.1,ទំព័រ ២។ (ជូនដំណឹងអំពីអវត្តមានរបស់ អៀង សារី នួន ជា និង ខៀវ សំផន ក្នុងបន្ទប់សវនាការ ដោយសារ"បញ្ហាសុខភាព"ដែលពុំទាន់បានធូរស្បើយ)។

[65] *សូមមើលដូចខាងលើ* កថាខណ្ឌ២៣ *និង*ជើងទំព័រ ៦៣ និង*សូមមើលផ្នែកខាងលើ*កថាខណ្ឌ ៤៦ ដល់ ៥០។

[66] *សូមមើល* ប្រតិចារឹក (ភាសាអង់គ្លេស) ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ ឯកសារ E1/137.1 កថាខណ្ឌ៤៩-៥០។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា "ប្រឆាំងនឹងការបដិសេធជាក់ស្តែងដោយមិនបានសម្រេចលើសំណើសុំឲ្យធ្វើចំណាត់ការជាបន្ទាន់តាមវិធាន៣៥នៃវិធានផ្ទៃក្នុង" ឯកសារ E189/2/3 ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ កថាខណ្ឌ៥ *និង* ជើងទំព័រ១៣។

[67] សូមប្រៀបធៀប វិធាន ១០៤ និង ១១០ ដល់ ១១១ និង ១១៣ នៃវិធានផ្ទៃក្នុង។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៧។ មាត្រា ៣៩៨, ៤០៥ ដល់ ៤០៦ , ៤៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៧។

[68] *សូមមើល ឧទាហរណ៍* ប្រតិចារឹក, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២, ឯកសារលេខ E1/136.1 ទំព័រ ៨ ("[លោក IANUZZI តំណាងឲ្យនួន ជា] ខ្ញុំគិតថា យើងគួរកំណត់សញ្ញាណមួយដាច់ខាតតែម្តង និងសម្រាប់ទស្សនៈ ទាំងអស់ដែល ថានឹងមានសវនាការមួយទៀតក្នុសំណុំរឿង ០០២/០១ ជាសវនាការដែលយើងកំពុងស្តាប់សក្ខីកម្មនាពេលនេះ និងមិនមានសវនាការមួយទៀតទេ។ ខ្ញុំគិតថា អ្នកទាំងអស់គ្នានឹងយល់ស្របជាមួយនឹងបញ្ហានេះដែរ"); ប្រតិចារឹក (អង់គ្លេស), ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២, ឯកសារលេខ E1/135.1 ទំព័រ ៣០ ("[លោក IANUZZI តំណាងឲ្យ នួន ជា ៖] ហើយយើងយល់បន្ថែមទៀត [...] ថា ហេតុផលចំពោះបញ្ហានេះ គឺត្រូវដាក់ចេញនូវមូលដ្ឋានមួយ ដូចដែលបានអនុវត្តកន្លងមក សម្រាប់ការជំនុំជម្រះ

ទោះបីជាអង្គជំនុំជម្រះសាលាដំបូង បានធ្វើសេចក្តីថ្លែងដែលបង្កប់ន័យថា សំណុំរឿង ០០២/០១ នឹងជាការជំនុំជម្រះក្តីតែមួយប៉ុណ្ណោះ ដែលនឹងត្រូវចេញសាលក្រម[69]។

25. ផ្អែកលើសំអាងហេតុដែលលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ក្នុងនាមជាសេចក្តីសម្រេចស្ថាពរលើទម្រង់នៃការបំបែកកិច្ចដំណើរការនីតិវិធី នៅក្នុងសំណុំរឿង ០០២ សេចក្តីសម្រេចដែលត្រូវបានជំទាស់ អាចធ្វើឱ្យផ្អាកកិច្ចដំណើរការនីតិវិធី ទាក់ទិននឹងបទចោទទាំងអស់ដែលឋិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ ហើយការផ្អាកកិច្ចដំណើរការនីតិវិធីបែបនេះ មិនបានសន្យាច្បាស់លាស់គ្រប់គ្រាន់នៃការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីឡើងវិញ ដែលអាចចេញសាលក្រមលើអង្គសេចក្តីនោះទេ។ អាស្រ័យហេតុដូចនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សេចក្តីសម្រេចដែលត្រូវបានជំទាស់ ដែលបដិសេធចោលការរួមបញ្ចូលមន្ទីរ ស-២១ និងស្រុក១២ ក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីទាក់ទិននឹងបទចោទទាំងនោះ។

26. ហេតុដូចនេះ បណ្តឹងសាទុក្ខភ្លាមៗ អាចទទួលយកបាន ផ្អែកតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង។

---

ដែលត្រូវកាត់បន្ថយពេលវេលាឱ្យខ្លីក្នុងពេលអនាគត [...] នៅក្នុងសំណុំរឿង ០០២ 002 – យ៉ាងហោចណាស់ ក៏អាចចាត់ទុកជាទ្រឹស្តីដែរ។ ហើយខ្ញុំចង់និយាយត្រង់ចំណុចនេះថា យើងឯកភាពទាំងស្រុងជាមួយនឹងអ្វីៗដែលលោក CAYLEY បានលើកឡើងពាក់ព័ន្ធនឹងបញ្ហានេះ នៅពេលគាត់បាននិយាយក្នុងសវនាការពីពេលមុន ដែលថា បញ្ហានេះនឹងមិនកើតមានឡើងឡើយ");។ ប្រតិចារឹក, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២, ឯកសារ E1/114.2 ទំព័រ ១៩ ដល់ ២០ ("[លោក PAUW តំណាងឱ្យ នួន ជា ៖] ចំណុចចុងក្រោយមួយទៀត សហព្រះរាជអាជ្ញាបានលើកឡើងពីបញ្ហានេះកាលពីសប្តាហ៍មុន [នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ]។ ហើយតាមពិត ប្រសិនបើខ្ញុំយល់សហព្រះរាជអាជ្ញាមិនច្រឡំទេនោះ សហព្រះរាជអាជ្ញាចង់និយាយថា ៖ បើនិយាយឱ្យសាមញ្ញ និងស្មោះត្រង់ទៅ ឱកាសក្នុងការបើកសវនាការជាលើកទីពីរនៅចំពោះមុខអង្គជំនុំជម្រះ មានតិចតួចណាស់។ យើងកំពុងតែធ្វើការជំនុំជម្រះរឿងក្តីដែលមានជនជាប់ចោទមានវ័យចំណាស់ មូលនិធិកំពុងមានភាពខ្សត់ខ្សោយ ហើយវាមិនទំនងថានឹងមានករណីទីពីរ នៅពេលអនាគតឡើយ។ ដូច្នេះ យើងគិតថា វាជាសំខាន់ដែលថា បញ្ហាទាំងអស់ដែលបានកើតមាននៅក្នុងសំណុំរឿងនេះត្រូវបានបញ្ជាក់ឱ្យបានច្បាស់លាស់")។

[69] សូមមើលសេចក្តីសម្រេចលើសំណើសុំឱ្យពិចារណាឡើងវិញ កថាខណ្ឌ១១ ("ដោយពិចារណាថា ពិតជាមានក្តីបារម្ភមួយថាតើ ជនជាប់ចោទនឹងអាចចូលរួមទាំងផ្លូវកាយ និងស្មារតីនៅក្នុងការជំនុំជម្រះដែលមានរយៈពេលវែង ឬយ៉ាងណា ដូចដែលសហព្រះរាជអាជ្ញាលើកឡើងនោះ អង្គជំនុំជម្រះបានចាត់ទុកវិធានការទាំងនេះថាមានសារៈសំខាន់ដើម្បី "[ការពារ]ផលប្រយោជន៍ជាសារវ័ន្តរបស់ជនរងគ្រោះក្នុងការទទួលបាននូវយុត្តិធម៌ប្រកបដោយអត្ថន័យ និងទាន់ពេលវេលា ព្រមទាំងការពារបាននូវសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស នៅក្នុងសំណុំរឿង ០០២ ទៀតផង"។") *សូមមើលផងដែរ* ដីកាបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៨។

# IV. អង្គសេចក្តី

27. ដូចដែលបានរំឭកពីខាងលើ នៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដែលត្រូវបានជំទាស់នៅក្នុងទម្រង់ជាអនុស្សរណៈ ដែលនៅក្នុងនោះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលស្រុក ១២ និងមន្ទីរសន្តិសុខ ស ២១ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ប៉ុន្តែអង្គជំនុំជម្រះបានអនុញ្ញាត តាមសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលទួលពោធិ៍ជ្រៃ[70]។

28. សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ កំហុសអង្គហេតុ និងកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយបានបដិសេធមិនដាក់បញ្ចូលស្រុក ១២ និងមន្ទីរ ស ២១ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១[71]។ ជាពិសេស សហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការចេញសេចក្តីសម្រេចនៅក្នុងទម្រង់ និងខ្លឹមសារមិនគ្រប់គ្រាន់[72]។ សហព្រះរាជអាជ្ញាបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងមាន កំហុសនៅក្នុងការខកខានមិនបានធ្វើការពិចារណាថា តើការចោទប្រកាន់ទាំងឡាយនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ គឺជាតំណាងដ៏សមហេតុផលនៃការចោទប្រកាន់ទាំងឡាយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែរ ឬយ៉ាងណា[73]។ សហព្រះរាជអាជ្ញាបានលើកឡើងថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកដោយភ័ន្តច្រលំលើការពិចារណាដែលមិនពាក់ព័ន្ធ និងផ្អែកលើកត្តាយល់ខុសទាំងឡាយដែលប៉ះពាល់ដល់រយៈពេលនៃសវនាការ[74]។ លើសពីនេះទៀត សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង បានយល់ច្រលំអំពីចំណងទាក់ទងរវាងបញ្ហាបច្ចុប្បន្ននៅក្នុងសំណុំរឿង ០០២/០១ និងទីតាំងឧក្រិដ្ឋកម្មបន្ថែម

---

[70] *សូមមើលខាងលើ* កថាខណ្ឌ ៧ *ដោយយោងលើ សេចក្តីសម្រេចដែលត្រូវបានជំទាស់* កថាខណ្ឌ ២-៣។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ទួលពោធិ៍ជ្រៃនឹងត្រូវដាក់បញ្ចូលតែករណី "ដោយហេតុថា ការកាប់សម្លាប់ទាំងនេះ... បានកើតឡើងភ្លាមៗបន្ទាប់ពីមានការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ... ប៉ុន្តែពុំសំដៅគ្របដណ្តប់លើការកាប់សម្លាប់នានាផ្សេងទៀតនៅទីតាំងនេះ ដែលបានកើតឡើងនៅចន្លោះឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៧ ឡើយ"។ *សូមមើល* សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣។

[71] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ១-៣, ២១-៨៦។

[72] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣, ៤២-៤៨។

[73] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣, ២១-៤១។ *សូមមើលផងដែរ* ការឆ្លើយតបទៅ នួន ជា កថាខណ្ឌ ៥-៦។

[74] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣, ៤៩-៦៨, ៨២-៨៦។ *សូមមើលផងដែរ* ការឆ្លើយតបទៅ នួន ជា កថាខណ្ឌ ៧-១៥។

ដែលបានស្នើឡើង[75]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលលើកឡើងថា ការពង្រីកវិសាលភាពសវនាការក្នុងសំណុំរឿង ០០២/០១ ដើម្បីដាក់បញ្ចូលមន្ទីរសន្តិសុខ ស ២១ និងស្រុក ១២ គឺធ្វើឡើងដើម្បីផលប្រយោជន៍យុត្តិធម៌ និងហេតុនេះសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលកែប្រែសេចក្តីសម្រេចដែលត្រូវបានជំទាស់[76]។

29. នួន ជា និង ខៀវ សំផន បានឆ្លើយតបថា បណ្តឹងសាទុក្ខភ្លាមៗគឺធ្វើឡើងដោយគ្មានមូលដ្ឋាន និងគួរតែត្រូវបានបដិសេធចោលដូច្នេះឯង[77]។ អៀង សារី ពុំបានធ្វើសេចក្តីសន្និដ្ឋានជាក់លាក់ណាមួយលើអង្គសេចក្តីនេះទេ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគាំទ្របណ្តឹងសាទុក្ខភ្លាមៗទាំងមូល និងស្នើសុំឱ្យមានការយល់ព្រមតាមសំណូមពររបស់សហព្រះរាជអាជ្ញា[78]។

## ក. ទម្រង់

30. ទាក់ទងទៅនឹងទម្រង់នៃសេចក្តីសម្រេចដែលរងការជំទាស់ សហព្រះរាជអាជ្ញាលើបញ្ហាដោយបង្ហាញនូវអង្គហេតុថា សេចក្តីសម្រេចនេះ ត្រូវបានចេញក្នុងទម្រង់ជា អនុស្សរណៈ ដោយលើកឡើងថា ភាពមិនគ្រាន់ផ្នែកទម្រង់ បង្កើតឱ្យមានភាពមិនច្បាស់លាស់[79]។ ពាក់ព័ន្ធនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា៖

> សេចក្តីសម្រេចរបស់តុលាការត្រូវតែបង្ហាញ *ការបញ្ជាក់ណាមួយ*អំពីចំណាត់ការតាមផ្លូវតុលាការមួយដែលច្បាប់អនុញ្ញាត។ ត្រង់ចំណុចនេះ ជាការចាំបាច់ដែលសេចក្តីសម្រេចមួយ តាមផ្លូវតុលាការត្រូវចាត់ការលើបញ្ហាអង្គច្បាប់មួយ ដែលស្ថិតនៅចំពោះមុខខ្លួនឱ្យបានច្បាស់លាស់។ ហេតុដូច្នេះ សេចក្តីសម្រេចតាមផ្លូវតុលាការ គួរតែប្បីមានផ្នែកមួយដែលមានអានុភាព ("ខ សម្រាប់អនុម័តច្បាប់" ឬ "ផ្នែកសម្រេចសេចក្តី") ដែលដោះស្រាយចំពោះអង្គសេចក្តី ហើយ/ឬ បញ្ហានីតិវិធី ដោយ

[75] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣, ៦៩-៨១។ *សូមមើលផងដែរ* ការឆ្លើយតបទៅ នួន ជា កថាខណ្ឌ ១៦-២៦។

[76] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣, ៨៧។ *សូមមើលផងដែរ* ការឆ្លើយតបទៅ នួន ជា កថាខណ្ឌ ២៧។ ការឆ្លើយតបទៅ ខៀវ សំផន ជា កថាខណ្ឌ ១១។

[77] សារណាឆ្លើយតបរបស់ នួន ជា កថាខណ្ឌ ៦-៣៦។ សារណាឆ្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ២៥-៥៦។

[78] សារណាឆ្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១-១១។

[79] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤៥-៤៦។

បង្កើត កែប្រែ បដិសេធចោល ឬទទួលយកនូវទំនាក់ទំនងដែលសំអាងលើច្បាប់ ដែលមានជាប់ពាក់ព័ន្ធទៅនឹងភាគីនានា[80]។

អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថែមទៀតថា សេចក្តីសម្រេចដែលត្រូវបានជំទាស់បានច្រានចោលសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលស្រុក ១២ មន្ទីរ ស ២១ និងទួលពោធិ៍ជ្រៃ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ យ៉ាងដាច់ណាត់ ដោយខ្លួនយល់ព្រមដាក់បញ្ចូលតែទួលពោធិ៍ជ្រៃមួយប៉ុណ្ណោះ។ ហេតុនេះ សេចក្តីសម្រេចដែលរងការជំទាស់ មាន*ការបញ្ជាក់*ពីចំណាត់ការតាមផ្លូវតុលាការមួយដែលច្បាប់អនុញ្ញាត ទោះបីជាមានកង្វះនូវទម្រង់ច្បាស់លាស់ក៏ដោយ។ អង្គជំនុំជម្រះតុលាការកំពូលបង្ហាញថា ក្នុងករណីដែលច្បាប់មិនតម្រូវឱ្យមានទម្រង់មួយជាក់លាក់ ឬការបញ្ជាក់ជាផ្លូវការនូវចំណាត់ការរបស់តុលាការ ការអនុវត្តចាកប្រាស់ពីទម្រង់ និងនិមិត្តសញ្ញារបស់តុលាការ មិនបានចាត់ទុកសកម្មភាពនេះ មោឃៈបានទេ។ ផ្ទុយទៅវិញ សកម្មភាពនេះត្រូវតែត្រួតពិនិត្យឡើងវិញ ទៅលើទិដ្ឋភាពយុត្តិធម៌ ភាពច្បាស់លាស់គ្រប់គ្រាន់ចំពោះអត្ថិភាព ខ្លឹមសារ និងផលវិបាកនៃកិច្ចដំណើរការនីតិវិធី។ ក្នុងន័យនេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ពីដំបូងហើយថា តាមឆន្ទានុសិទ្ធិ "ខ្លួននឹងចេញសេចក្តីសម្រេចជាអនុស្សរណៈ ដែលបញ្ហារឿងក្តី ជាធំជាប់ទាក់ទងទៅនឹងការរៀបចំសវនាការ"[81]។ ដូចនេះ នៅពេលដែល នេះជាការប្រសើរសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការចេញសេចក្តីសម្រេចទាំងអស់របស់ខ្លួនក្នុងទម្រង់ជាផ្លូវការមួយ មិនថាសេចក្តីសម្រេចលើអង្គសេចក្តី ឬលើនីតិវិធីនោះទេ អង្គជំនុំជម្រះតុលាការកំពូលមិនយល់ឃើញថា ការដែលគ្មានទម្រង់បែបបទនៅក្នុងករណីពិសេសនេះ បង្កើតបានជាកម្រិតនៃភាពមិនច្បាស់លាស់ដែលជាកំហុសស្តែងឱ្យឃើញតាមការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្កឱ្យមានការប៉ះពាល់ដល់សិទ្ធិរបស់សហព្រះរាជអាជ្ញាឡើយ។

## ខ. ខ្លឹមសារ

---

[80] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឯកសារ E176/2/1/4 ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ("សេចក្តីសម្រេចតាមវិធាន ៣៥") កថាខណ្ឌ ២៥ (ឯកសារយោងផ្ទៃក្នុងត្រូវបានលុបចោល)។

[81] អនុស្សរណៈរបស់ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "ផ្នែកសម្រេចសេចក្តីរបស់អង្គជំនុំជម្រះសាលាដំបូងលើសារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងគោលបំណងសុំការពិចារណាឡើងវិញ និងកែតម្រូវលើអនុស្សរណៈ លេខ E62/3/10/4" (E62/3/10/4) និង សំណើសុំ E117, E117/2 ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១ ទំព័រ ៣។

31. ទាក់ទងទៅនឹងខ្លឹមសារនៃសេចក្តីសម្រេចដែលរងការជំទាស់នេះ សហព្រះរាជអាជ្ញាលើកឡើងជាសំខាន់ថា ក្នុងការមិនបញ្ចូល ស្រុក ១២ និង ស ២១ អង្គជំនុំជម្រះខកខាន ក្នុងការពិចារណា ថាតើវិសាលភាពនៃសំណុំរឿង ០០២/០១ តំណាងឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយនិងកត្តាទាំងឡាយដែលអង្គជំនុំជម្រះសាលាដំបូង ផ្អែកលើនោះ មិនជាប់ពាក់ព័ន្ធ បកស្រាយមិនបាន ត្រឹមត្រូវ ឬចាកឆ្ងាយការពិត[82]។

32. នៅក្នុងការសម្រេច មិនដាក់បញ្ចូលស្រុក ១២ និងមន្ទីរសន្តិសុខ ស ២១ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា៖

> ជាបឋម មូលហេតុនៃការយល់ឃើញដូច្នេះ គឺមកពីការដាក់បញ្ចូលធាតុផ្សំទាំងនេះ (មិនថាដោយសារចំនួនសាក្សីដែលភាគីបានស្នើសុំកោះហៅ ការលំបាកដែលបានរំពឹងទុកក្នុងការកំហិតវិសាលភាពនៃចំណុចអង្គហេតុបន្ថែមដែលត្រូវបានស្នើសុំទាំងនេះ ឬការជំទាស់របស់មេធាវីការពារក្តី ដែលអាចមានចំពោះចំណុចអង្គហេតុបន្ថែមទាំងនេះឡើយ) នឹងអាចធ្វើឱ្យសវនាការលើសំណុំរឿង ០០២/០១ អូសបន្លាយពេលយូរ។ អង្គជំនុំជម្រះនៅតែយល់ឃើញថា ទីតាំងឧក្រិដ្ឋកម្មបន្ថែមទាំងនេះ មិនជាប់ពាក់ព័ន្ធជិតស្និទ្ធទៅនឹងការចោទប្រកាន់ចំពោះអង្គហេតុក្នុងសំណុំរឿង ០០២/០១ ឬថា ការដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មទាំងនេះ មិនសមស្របតាម លំដាប់លំដោយត្រឹមត្រូវនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២ ដូចដែលមានរៀបរាប់ក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនោះទេ (ឯកសារ E124)។ ជាចុងក្រោយ ទោះបីជាអង្គជំនុំជម្រះយល់ឃើញថា ខ្លួនត្រូវធានាឱ្យមានសវនាការដោយឆាប់រហ័សយ៉ាងណាក៏ដោយ ក៏កន្លងមកអង្គជំនុំជម្រះបានចំណាយពេលវេលាអស់ជាច្រើន ដែលចាំបាច់ក្នុងការវាយតម្លៃ និងបន្ទាប់មកពិនិត្យមើល និងវាយតម្លៃឡើងវិញនូវបញ្ហាសម្បទា និងបញ្ហាស្មារតីរបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ។ម្យ៉ាងវិញទៀត ស្ថានភាពសុខភាពនាពេលបច្ចុប្បន្នរបស់ជនជាប់ចោទ អៀង សារី និងបញ្ហាស្មុគស្មាញជាហូរហែរនៃការរៀបចំសវនាការ រឹតតែធ្វើឱ្យអង្គជំនុំជម្រះរារែកក្នុងការពង្រីកវិសាលភាពទូលំទូលាយនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១[83]។

33. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការរៀបរាប់របស់អង្គជំនុំជម្រះនូវលក្ខខណ្ឌ នៃសំណុំរឿងដែលត្រូវបានបំបែកនោះ ធ្វើឱ្យមានការបារម្ភមួយជាបឋម។ ការពិចារណាទៅលើប្រសិទ្ធិភាព

---

[82] *សូមមើលខាងលើ* កថាខណ្ឌ ២៨។

[83] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២។

និងយុត្តិធម៌ តម្រូវឱ្យអនុវត្តតាមគោលការណ៍ជាទូទៅ ដែលមានចែងក្នុងច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក ក៏ដូចជា នៅក្នុងយុត្តាធិការនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលថា បទចោទពាក់ព័ន្ធនឹងព្រឹត្តិការណ៍ស្រដៀងគ្នាចំពោះជនជាប់ចោទជាច្រើនរូប គប្បីត្រូវជំនុំជម្រះនៅក្នុងកិច្ចដំណើរការនីតិវិធីបញ្ចូលគ្នា[84]។ ការបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានសម្រេចរួចហើយនោះ ពុំមានចែងនៅក្នុងច្បាប់កម្ពុជានោះឡើយ ហើយតុលាការព្រហ្មទណ្ឌអន្តរជាតិ *ពិសេស* មានការស្ទាក់ស្ទើរក្នុងការទទួលយកសំណើសុំបំបែកកិច្ចដំណើរការនីតិវិធីនេះ[85]។ ការបំបែកនេះមានលក្ខណៈចាំបាច់ នៅពេលដែល

---

[84] សូមមើវិធាន ៧៩(២) នៃវិធានផ្ទៃក្នុង ("នៅពេលដែលអង្គជំនុំជម្រះសាលាដំបូង ទទួលបានដីកាបញ្ជូនរឿងទៅជំនុំជម្រះច្រើន ដែលមានការជាប់ពាក់ព័ន្ធគ្នា អង្គជំនុំជម្រះសាលាដំបូងអាចដីការមួយឱ្យដាក់បញ្ចូលគ្នានូវដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំង អស់នោះ"); មាត្រា ២៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("កាលណាតុលាការបានទទួលនីតិវិធីច្រើន ដែលមានអង្គហេតុទាក់ទងគ្នា តុលាការអាចបង្គាប់ឱ្យបញ្ចូលនីតិវិធីទាំងនោះជាមួយគ្នាបាន"); វិធាន ៤៨ នៃវិធានរបស់តុលាការ ICTY ("ជនដែលត្រូវបានចោទប្រកាន់ ពីបទឧក្រិដ្ឋដូចគ្នា ឬខុសគ្នា ដែលបានប្រព្រឹត្តឡើងក្នុងពេលដូចគ្នា អាចត្រូវបានចោទប្រកាន់ និងជំនុំជម្រះបញ្ចូលគ្នា"); វិធាន ៤៨ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉ូហ្វាន់ដា ("វិធានរបស់តុលាការ ICTR"); វិធាន ៤៨*ស្ទួន* នៃវិធានរបស់តុលាការ ICTR ("បុគ្គលដែលត្រូវបានចោទប្រកាន់ដាច់ដោយឡែក ពីឧក្រិដ្ឋ ដូចគ្នា ឬខុសគ្នាដែលបានប្រព្រឹត្តឡើងក្នុងពេលដូចគ្នា អាចធ្វើការជំនុំជម្រះរួមគ្នាបាន ដោយមានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង"); រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Jadranko PRLIĆ, និងជនដទៃទៀត* ,សំណុំរឿងលេខ IT-04-74-PT, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី សុំឱ្យមានការជំនុំជម្រះដាច់ដោយឡែក និងការបំបែកបទចោទ ចុះថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៥ ("សេចក្តីសម្រេចលើ *Prlić* "), កថាខណ្ឌ ២៣ ("អង្គជំនុំជម្រះចាត់ទុកថា នេះជាប្រយោជន៍យុត្តិធម៌ ក្នុងការធ្វើការជំនុំជម្រះបញ្ចូល") ។ *រឿងក្តីរដ្ឋអាជ្ញាទល់នឹង Théoneste BAGOSORA et al.*, សំណុំរឿងលេខ ICTR-98-41-T, សេចក្តីសម្រេចលើសំណើរបស់ Ntabakuze សុំបំបែក និងបង្កើតដីកាកំណត់កាលបរិច្ឆេទសម្រាប់ធ្វើបទបង្ហាញនៃសាក្សីរបស់អយ្យការ ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៣ ("សេចក្តីសម្រេចលើ *Bagosora* "), កថាខណ្ឌ ២១។ *សូមមើល* ផងដែរ វិធាន ៤៩ នៃវិធាន របស់តុលាការ ICTR និង ICTY ("មានបទឧក្រិដ្ឋពីរ ឬច្រើន អាចត្រូវបានបញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះតែមួយប្រសិនបើ លំដាប់នៃអំពើដែលបានប្រព្រឹត្តរួមគ្នានោះ គឺជាដំណើរការដូចគ្នា ហើយបទឧក្រិដ្ឋនេះ ត្រូវបានប្រព្រឹត្តឡើងដោយជនជាប់ចោទតែមួយ")។

[85] រឿងក្តី រដ្ឋអាជ្ញាទល់នឹង *Pauline NYIRAMASUHUKO និង Arsène Shalom NTAHOBALI*, សំណុំរឿងលេខ ICTR-08-42-T/ICTR-97-21-T, សេចក្តីសម្រេចលើសំណើរបស់ Nyiramasuhuko សុំបំបែកកិច្ចដំណើរការនីតិវិធី ការជំនុំជម្រះថ្មី ការផ្អាកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទិ ០៧ ខែ មេសា ឆ្នាំ ២០០៦ សេចក្តីសម្រេចលើ *Bagosora*។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Duško SIKIRICA, ជនដទៃទៀត,* សំណុំរឿងលេខ IT-95-8-PT សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ Kolundzija សុំការបំបែកបទចោទ និង/ឬ ការបំបែកនៃការជំនុំជម្រះ ចុះថ្ងៃទិ ០២ ខែ សីហា ឆ្នាំ ២០០០ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Radoslav BRĐANIN និង Momir TALIĆ*, សំណុំរឿងលេខ IT-99-36-T, សេចក្តីសម្រេចលើសំណើរបស់ Momir Talićសុំការជំនុំជម្រះដាច់ដោឡែក និងសុំការអនុញ្ញាតដាក់ការឆ្លើយតប ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០០; *រឿងក្តីរដ្ឋអាជ្ញា*

ការបំបែកនេះជាប់ពាក់ព័ន្ធទៅនឹងការបំបែកជនជាប់ចោទម្នាក់ចេញពីកិច្ចដំណើរនីតិវិធីបញ្ចូលគ្នានោះ[86]។ ហេតុនេះ សេចក្តីសម្រេចលើការបំបែកនេះ គឺជាករណីពិសេសចំពោះការជំនុំជម្រះបញ្ចូលគ្នា។

34. ដូចដែលបានរំឭកខាងលើ អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាបំបែកសំណុំរឿង ដោយអនុលោមតាមវិធាន ៨៩*ស្ទួនពីរ*នៃវិធានផ្ទៃក្នុង ដែលបានបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ទៅជាការជំនុំជម្រះដាច់ដោយឡែក[87]។ វិធាន ៨៩*ស្ទួនពីរ*នៃវិធានផ្ទៃក្នុងចែងថា:

> នៅពេលប្រយោជន៍យុត្តិធម៌តម្រូវ នៅក្នុងដំណាក់កាលណាមួយ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ឬច្រើនរូប និងផ្នែកដែលពាក់ព័ន្ធនឹងបទចោទខ្លះ ឬ ទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ រឿងក្តីដែលត្រូវបានបំបែកត្រូវយកមកជំនុំជម្រះ និងវិនិច្ឆ័យ ចេញសាលក្រមទៅតាមលំដាប់លំដោយដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសមស្រប។

35. អត្ថន័យនៃវិធាន ៨៩*ស្ទួនពីរ*នៃវិធានផ្ទៃក្នុងបង្ហាញថា សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីមិនមែនជាឆន្ទានុសិទ្ធិសុទ្ធសាតនោះទេ សេចក្តីសម្រេចនេះត្រូវតែផ្តល់ យុត្តិកម្មដោយផ្អែកលើ"ផល

---

*ទល់នឹង* *Dario KORDIĆ* *និង* *Mario ČERKEZ*, សំណុំរឿងលេខ IT-95-14/2-PT, សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ Mario Čerkez សុំការជំនុំជម្រះដាច់ដោយឡែកចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៩៨។

[86] *សូមមើល ឧ. រឿងក្តី* *Aloys NTABAKUZE* *ទល់នឹង* *The Prosecutor*, សំណុំរឿងលេខ ICTR-98-41A-A, សាលក្រមចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ៧; *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Ratko MLADIĆ*, សំណុំរឿងលេខ IT-09-92-PT, សេចក្តីសម្រេចលើសំណុំរួមរបស់អយ្យការសុំការបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះ ធ្វើការជំនុំជម្រះដាច់ដោយឡែក និងកែប្រែដីកានេះ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើរឿងក្តី *Mladič*"); សេចក្តីសម្រេចលើរឿងក្តី *Prlić*; *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Pavle* Strugar *និង* *Vladimir KOVAČEVIĆ*, សំណុំរឿងលេខ IT-01-04-PT, សេចក្តីសម្រេចលើសំណើរបស់អយ្យការ សុំការជំនុំជម្រះដាច់ដោយឡែក និងដីកាកំណត់កាលបរិច្ឆេទលើសន្និសិទ្ធរបស់ អង្គបុរេ និងការចាប់ផ្តើមការជំនុំជម្រះលើជនជាប់ចោទ Pavle STRUGAR, ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣; *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Radoslav BRĐANIN* *និង* *Momir TALIĆ*, សំណុំរឿងលេខ IT-99-36-T, សេចក្តីសម្រេចលើសំណើផ្ទាល់មាត់របស់អយ្យការ សុំការបំបែកការជំនុំជម្រះ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០២; វិធាន ៨២(ខ) នៃវិធានរបស់ ICTY("អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ថា ជនដែលត្រូវបានចោទប្រកាន់រួមគ្នា តាមវិធាន ៤៨ ត្រូវជំនុំជម្រះដាច់ដោយឡែកពីគ្នា ប្រសិនបើយល់ថាចាំបាច់ ដើម្បីជៀសវាងវិវាទលើផលប្រយោជន៍ដែល អាចបង្កឱ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជនជាប់ចោទ ឬ ដើម្បីការពារផលប្រយោជន៍យុត្តិធម៌")។

[87] *សូមមើលខាងលើ* កថាខណ្ឌ ៥។

ប្រយោជន៍យុត្តិធម៌” ប៉ុន្តែ សេចក្តីសម្រេចនេះ មិនបានផ្តល់នូវការណែនាំចំពោះកាលៈទេសៈអ្វី ក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវបាន។ តាមទស្សនៈរបស់អង្គជំនុំជម្រះតុលាការកំពូល“ផលប្រយោជន៍យុត្តិធម៌” ក្នុងកាបំបែក ត្រូវតែបកស្រាយដោយបង្ហាញនូវលក្ខខណ្ឌ ដែលជនជាប់ចោទ និង/ឬ បទចោទដែលបានជំនុំជម្រះដាច់ដោយឡែកនោះ បម្រើឱ្យគោលដៅនៃកិច្ចដំណើរការនីតិវិធី និងគោលការណ៍ ដែលជាមូលដ្ឋានសំអាង។ ដូចដែលបានយល់កន្លងមក “ផលប្រយោជន៍យុត្តិធម៌”ក្នុងការបំបែក នឹងបង្កើតឱ្យមានកត្តាផ្សេងៗជាច្រើន ក្នុងការសម្រេចទៅតាមករណីជាក់ស្តែង ក្រោយពីបានធ្វើការពិចារណាថាតើ អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេច ក្នុងការបំបែកសំណុំរឿងមួយ។ ប៉ុន្តែ ទោះបីជាមានដ៏ទូលំទូលាយឆន្ទានុសិទ្ធិដែលបានផ្តល់ឱ្យសាលាដំបូងក្នុងការសម្រេចលើការបំបែកក៏ដោយ “ផលប្រយោជន៍យុត្តិធម៌” ចាំបាច់ត្រូវតែបង្ហាញជាមួយសំអាងហេតុគ្រប់គ្រាន់ ដែលលើកឡើងពីកាលៈ ទេសៈជាប់ពាក់ព័ន្ធ និងច្បាស់លាស់ ហើយចាំបាច់ត្រូវពន្យល់នូវអានុភាពរួមទៅលើសំណុំរឿងដែលបាន បំបែកនោះឱ្យបានក្បោះក្បាយទាំងស្រុង។

36. យោងតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូល ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា កត្តាផ្សេងៗដែលជាប់ពាក់ព័ន្ធទៅនឹងភាពបន្ទាន់នៃកិច្ចដំណើរការនីតិវិធី និងតាមលំដាប់លំដោយ ត្រឹមត្រូវនៃសំណុំរឿង ០០២/០១ គឺជាការសមស្របមួយក្នុងការចេញនូវសេចក្តីសម្រេចដែលរងការជំទាស់នេះ ការសម្រេចនេះ មិនបានបង្ហាញឱ្យឃើញថាមានភាពមិនសមហេតុផលនោះឡើយ តាមការបង្ហាញលើកដំបូង។ ទាក់ទងនឹងការជំទាស់ដែលថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយមិនបានពិចារណាលើភាពជាតំណាងឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ការពិតដែលថា អង្គជំនុំជម្រះសាលាដំបូង មិនបានលើកកត្តានេះឱ្យបានច្បាស់លាស់ មិនមែនមានន័យថា អង្គជំនុំជម្រះមិនធ្វើការពិចារណាលើបញ្ហានោះទេ។ អង្គជំនុំជម្រះសាលាដំបូង មិនតម្រូវឱ្យបញ្ជាក់រាល់សំអាងហេតុលើការយល់ឃើញរបស់ខ្លួននោះឡើយ[88]។ ប៉ុន្តែ យោងតាមសារៈសំខាន់ និងទំហំនៃបញ្ហាទាំងមូលនាពេលបច្ចុប្បន្ន ការមិនបានរៀបរាប់ឱ្យបានពេញលេញនូវសំអាងហេតុនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន *តាមសេចក្តីបញ្ជាក់ដំបូង* បានបង្ហាញឱ្យឃើញនូវការកង្វះការពិចារណាលើសំអាងហេតុ និងការពិចារណាលើកត្តាដែលជាប់ពាក់ព័ន្ធ។

---

[88] *សូមមើលឧទា. រឿងក្តី* Dominique NTAWUKULILYAYO *ទល់នឹង* The Prosecutor, សំណុំរឿងលេខ ICTR-05-82-A, សាលក្រម, ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១, កថាខណ្ឌ ៤៥, ១៣៥, ១៥២ , ជើងទំព័រ ៤០៣, *និងសេចក្តីយោងដែលលើកឡើងមកជាមួយ* ។

37. ទោះបីជាយ៉ាងណាក៏ដោយ សំអាងបន្ថែមទៀត អាចត្រូវបានរកឃើញនៅក្នុងសេចក្តីសម្រេចពីមុនៗរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងដីកាបំបែកសំណុំរឿង ០០២។ ដូចដែលបានកត់សម្គាល់ពីដំបូង អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សេចក្តីសម្រេចដែលរងការជំទាស់ជាប់ទាក់ទងផ្ទៃក្នុងទៅនឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសម្រេចលើការពិចារណាឡើងវិញ ហើយបង្កើតវគ្គមួយនៃដំណើរការធ្វើការសម្រេចចិត្តដែលមានរយៈពេលមួយឆ្នាំ ដែលក្នុងដំណើរការនោះ បានបង្ហាញនូវការប្រកាសជាច្រើនលើបញ្ហាដដែល នៅក្នុងកាលៈទេសៈនៃអង្គហេតុ និងអង្គច្បាប់ដូចគ្នា[89]។ ហេតុដូច្នេះ ការពិនិត្យឡើងវិញដោយផ្អែកទៅលើអង្គសេចក្តីចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការដកចេញមន្ទីរ ស ២១ និងស្រុក ១២ ចេញពីវិសាលភាពនៃសំណុំរឿង ០០២/០១ តម្រូវឱ្យមានការពិនិត្យទៅលើដីកាបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសម្រេចស្តីលើការពិចារណាឡើងវិញ ជាពិសេសដោយដឹងថា វិសាលភាពនៃសំណុំរឿង ០០២/០១ មិនទាន់បានបញ្ចប់ជាស្ថាពរនៅឡើយមុនពេលចេញសេចក្តីសម្រេដែលរងការជំទាស់នេះ[90]។ ក្នុងន័យនេះ ដីកាបំបែកិច្ចដំណើរការនីតិវិធី សេចក្តីសម្រេចស្តីពីពិចារណាឡើងវិញ និងសេចក្តីសម្រេចដែលរងការជំទាស់ ក៏ដូចជាអនុស្សរណៈពាក់ព័ន្ធទាំងឡាយ បង្កើតសេចក្តីសម្រេចមួយដ៏ទូលំទូលាយ ទាក់ទងនឹងការបំបែក សំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០១ (“ការបំបែកសំណុំរឿង ០០២”)[91]។

38. ទោះបីជាសហព្រះរាជអាជ្ញា បានយល់ស្របជាមួយដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីជាគោលការណ៍ក៏ដោយ ក៏សហព្រះរាជអាជ្ញាបានជំទាស់ចំពោះការមិនមានសវនាការស្តាប់ទៅលើលក្ខខណ្ឌនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី មុនពេលដែលដីកានេះ ហើយបានជំទាស់ទៅលើទម្រង់ និងខ្លឹមសារ ឬការកង្វះខាតភាពច្បាស់លាស់ពាក់ព័ន្ធទៅនឹងការបំបែកកិច្ចដំណើរការនីតិវិធី ដែចាំបាច់ក្នុងការបំបែកនេះ[92]។ ដោយការលើកឡើងនូវទឡ្ហីករណ៍ដែលថា លក្ខខណ្ឌនៃដីកាសម្រេចបំបែកកិច្ចដំណើរការ

---

[89] *សូមមើលផងដែរផ្នែកខាងលើ* កថាខណ្ឌ ១៧។

[90] *សូមមើលផ្នែកខាងលើ* កថាខណ្ឌ ១៧ និង ជើងទំព័រ ៤៦។ *សូមមើលផងដែរផ្នែកខាងលើ* កថាខណ្ឌ ២៣។

[91] *សូមមើលផ្នែកខាងលើ* កថាខណ្ឌ ១៧។

[92] ការជូនដំណឹងពីសំណើសុំឱ្យពិចារណាឡើងវិញ កថាខណ្ឌ ២ ដល់ ៥, សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញ កថាខណ្ឌ ១ ដល់ ៦, ១៦, ២៤ ដល់ ៤៥។ សូមមើលផងដែរ ការជូនដំណឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពីសំណើសុំឱ្យពិចារណាឡើងវិញ កថាខន្ឌ ២ ដល់ ៣, ៥ ដល់ ៦, សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យពិចារណាឡើងវិញ កថាខណ្ឌ ១ ដល់ ២, ៤ ដល់ ១៥, ១៩ ដល់ ៤៨, សំណើរបស់សហព្រះរាជអាជ្ញា សុំការបញ្ជាក់បំភ្លឺលើវិសាលភាពនៃការជំនុះជម្រះទី ១ E124/9, ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ (“សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំការបញ្ជាក់ និងសេចក្តីសម្រេចដែលមានសំអាង

នីតិវិធី គឺមិនបានគិតទៅដល់ផលប្រយោជន៍របស់ខ្លួននោះ សហព្រះរាជអាជ្ញាបានព្យាយាមស្វែងរកនូវការពិចារណាឡើងវិញ ដោយបានស្នើសុំជាសំខាន់ឲ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យឡើងវិញនូវវិសាលភាពនៃសំណុំរឿង ០០២/០១ ដែលត្រូវតំណាងឲ្យបានច្រើននូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ[93] ។ ក្នុងការបដិសេធទៅលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញនោះ អង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់ថា វិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង បានផ្តល់ដល់អង្គជំនុំជម្រះនូវសមត្ថកិច្ចគ្រប់គ្រងសវនាការតាមឆន្ទានុសិទ្ធិដ៏ទូលំទូលាយ ដើម្បីឲ្យអង្គជំនុំជម្រះបំបែកសំណុំរឿងតាមឆន្ទានុសិទ្ធិរបស់ខ្លួន ហើយមិនបើកផ្លូវឲ្យប្តឹងសាទុក្ខភ្លាមៗនោះទេ[94]។ អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញបន្ថែមទៀតថា ការតម្រូវដែលមានលក្ខណៈចាប់បង្ខំ ដូចជាវិធាន ឲ្យមានការសាកសួរមតិពីសហព្រះរាជអាជ្ញា ព្រមទាំងតម្រូវឲ្យមានការពិចារណាពីការតំណាងដោយសមហេតុផលនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ មុនពេលធ្វើការសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីនោះ គឺ “មិនសមស្របទៅនឹង អ.វ.ត.ក នោះទេ នៅពេលដែលកិច្ចដំណើរការ

ហេតុ”), កថាខណ្ឌ ១ ដល់ ១៥, សំណើបន្ទាន់ពាក់ព័ន្ធវិសាលភាពនៃសវនាការទី ១ និងតម្រូវការសម្រាប់សេចក្តីសម្រេចដោយមានសំអាងហេតុ បន្ទាប់ពីមានសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, E124/10, ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ និងដាក់ចូលក្នុងសំណុំរឿង ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ ១ ដល់ ១៣, សំណើសុំឲ្យមានការពង្រីក, ១ ដល់ ៣៣, ចម្លើយតប [របស់ នួន ជា] ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញនូវដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី E124/5, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ កថាខណ្ឌ ៤ ដល់ ៥ (“ទោះបីជាសេចក្តីសម្រេចលើសំណើ [សុំឲ្យមានការពិនិត្យឡើងវិញ] នោះយ៉ាងណាក៏ដោយ ក៏មេធាវីការពារក្តី [នួន ជា] សង្ឃឹមថា អង្គជំនុំជម្រះសាលាដំបូង នឹងចេញសេចក្តីសម្រេចដោយសមស្របក្នុងពេលឆាប់ៗ។ (ដោយសន្មត) ក្នុងពេលណាមួយនោះជនជាប់ចោទ [នួន ជា] ចាំបាច់ត្រូវដឹងអំពីទំហំ និងវិសាលភាពពិតប្រាកដដែលប្រឆាំងនឹងរូបគាត់។ តែបន្ទាប់ពីរយៈបួនឆ្នាំយ៉ាងយូរ បញ្ហានេះនៅតែហួសពីសមត្ថភាពវិសាមញ្ញរបស់តុលាការនេះដដែល។ [...]ដោយពិចារណាអំពីសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការកាត់ក្តីមួយឆាប់រហ័ស មេធាវីការពារក្តីសូមជំទាស់នឹងការស្នើសុំឲ្យមានសវនាការដេញដោលលើបញ្ហានេះ និងរង់ចាំយ៉ាងខ្លាំង (មិនគិតទាំងការហាត់នឿយផងទេ) ដើម្បីអានអ្វីមួយដូចនឹងការចោទប្រកាន់ចុងក្រោយក្នុងពេលឆាប់ៗ”។ (ឯកសារយោងខាងក្នុងត្រូវបានលប់ចេញ)។

[93] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញ កថាខណ្ឌ ១ ដល់ ៣, ១៦ ដល់ ៤៥។ សូមមើលផងដែរ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យពិចារណាឡើងវិញ កថាខណ្ឌ ១, ៦ ដល់ ៤៨។

[94] សេចក្តីសម្រេចលើសំណើសុំឲ្យពិចារណាឡើងវិញ កថាខណ្ឌ ៥។ សូមមើលផងដែរ អនុស្សរណៈរបស់លោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា “សេចក្តីជូនដំណឹងអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើដែលនៅសេសសល់មុនសវនាការ (ឯកសារ E20, E132, E134, E135, E124/8, E124/9, E124/10, E136 និង E139) និង ការណែនាំបន្ថែមទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, E145, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ (“អនុស្សរណៈចុះ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១”), ទំព័រ ១។

នីតិវិធី [មិនមានការពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានផ្តួចផ្តើម និងកែសម្រួលដោយអយ្យការ ប៉ុន្តែផ្ទុយទៅវិញ] មានការពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបអង្កេត ត្រូវបានគ្រប់គ្រងដោយសមត្ថកិច្ចតុលាការ"[95]។ លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ដោយសារតែការចោទប្រកាន់ ឬបទចោទនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមានទំនាក់ទំនងបន្តបន្ទាប់គ្នា នៅក្នុងដីកាបំបែកសំណុំរឿងនោះ ហេតុដូច្នេះការជំនុំជម្រះដំណាក់កាលដំបូង មិនចាំបាច់គ្របដណ្តប់លើបទចោទទាំងមូល នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ"[96]។

39. ពាក់ព័ន្ធទៅនឹងសិទ្ធិប្តឹងសាទុក្ខ សហព្រះរាជអាជ្ញាបានលើកឡើងថា ការផ្តល់សិទ្ធិដល់អង្គជំនុំជម្រះ សម្រាប់ធ្វើការសម្រេចតាមឆន្ទានុសិទ្ធិក្នុងការគ្រប់គ្រងសវនាការនោះ គឺមិនមែនជាសិទ្ធិផ្តាច់មុខនោះទេ ហើយសិទ្ធិនេះក៏មិនរារាំងការពិនិត្យឡើងវិញដោយអង្គជំនុំជម្រះតុលាការកំពូលដែរ[97] ហើយទទ្បីករណ៍

---

[95] សេចក្តីសម្រេចលើសំណើសុំឲ្យពិចារណាឡើងវិញ កថាខណ្ឌ ៤។ សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងចំណុចនេះ គឺជាការឆ្លើយតបទៅនឹងសារណារបស់សហព្រះរាជអាជ្ញា ក្នុងសំណើសុំឲ្យពិចារណាឡើងវិញ ដែលថាលក្ខខណ្ឌតម្រូវ "ផលប្រយោជន៍យុត្តិធម៌" ក្នុងវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង មិនត្រូវបានកំណត់ឡើយ ដូច្នេះតម្រូវឲ្យពិនិត្យមើលលើការអនុវត្តកម្រិតអន្តរជាតិ ដើម្បីជាគោលការណ៍ណែនាំទៅលើបញ្ហានេះ។ សូមមើលសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញ កថាខណ្ឌ ១៧។ សហព្រះរាជអាជ្ញាពឹងផ្អែកយ៉ាងច្រើនទៅលើវិធាន ៧៣ស្ទួន នៃវិធានស្តីពីនីតិវិធី និងភស្តុតាង របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី("វិធានរបស់តុលាការ ICTY") ដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួនដែលថា សហព្រះរាជអាជ្ញាមានសិទ្ធិបញ្ចេញមតិក្នុងសវនាការ មុនពេលដែលដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីត្រូវបានចេញ ហើយសំណុំរឿងដែលបានបំបែកចាំបាច់ត្រូវតែតំណាងឲ្យសមហេតុផលដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ សូមមើលសំណើរសុំឲ្យពិចារណាឡើងវិញកថាខណ្ឌ ១៧ ដល់ ២៣, ២៩ ដល់ ៣២។ វិធាន ៧៣ស្ទួន នៃវិធានរបស់តុលាការ ICTY ចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធ "បន្ទាប់ពីបានស្តាប់រដ្ឋអាជ្ញា អង្គជំនុំជម្រះសាលាដំបូង ដើម្បីផលប្រយោជន៍យុត្តិធម៌ និងការជំនុំជម្រះដោយឆាប់រហ័ស ស្នើដល់រដ្ឋអាជ្ញាឲ្យកាត់បន្ថយចំនួននៃបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយនឹងធ្វើការកែសម្រួលចំនួននៃទីតាំងឧក្រិដ្ឋកម្ម ឬព្រឹត្តិការណ៍ដែលមាននៅក្នុងបទចោទមួយ ឬច្រើន ពាក់ព័ន្ធទៅនឹងភស្តុតាងដែលត្រូវបង្ហាញដោយរដ្ឋអាជ្ញា ដែលពាក់ព័ន្ធទៅនឹងកាលៈទេសៈពាក់ព័ន្ធ រួមមានឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ការកំណត់ប្រភេទនៃបទចោទ និងលក្ខណៈនៃបទចោទ ទីតាំងដែលបទឧក្រិដ្ឋទាំងនោះត្រូវបានគេចោទប្រកាន់ថាបានប្រព្រឹត្តិ ទំហំនៃឧក្រិដ្ឋកម្ម ព្រមទាំងជនរងគ្រោះនៃឧក្រិដ្ឋកម្ម *ដើម្បីតំណាងឲ្យបានសមស្របចំពោះបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់* (ដោយមានសេចក្តីបញ្ជាក់បន្ថែម)។

[96] សេចក្តីសម្រេចលើ សំណើរសុំឲ្យពិចារណាឡើងវិញ កថាខណ្ឌ ៩។

[97] បណ្តឹងសាទុក្ខបន្ទាន់បន្ទំ កថាខណ្ឌ ២៤ ដល់ ៣០។

មួយនេះក៏ទទួលបានការឯកភាពពីក្រុមមេធាវី នួន ជា ផងដែរ[98]។ អង្គជំនុំជម្រះតុលាការកំពូលសូមរំឭកថា សេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូង ទោះបីជាសេចក្តីសម្រេចខ្លឹមសារ ឬនីតិវិធី ដែលស្ថិតក្នុងវិសាលភាពនៃប្រភេទណាមួយក្នុងចំណោមប្រភេទទាំងបួន ដូចមានចែងក្នុងវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុងនោះ គឺអាចត្រូវប្តឹងសាទុក្ខបន្ទាន់បន្ទំ ហើយអាចត្រូវបានច្រានចោល ក្នុងករណីដែលសេចក្តីសម្រេចនោះមានកំហុសឆ្គងជាក់ស្តែង ក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្កឲ្យមានព្យសនកម្មដល់ម្ចាស់បណ្តឹងសាទុក្ខ[99]។

40. ពាក់ព័ន្ធនឹងសិទ្ធិផ្តល់ទស្សនយោបល់ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ដោយមានការព្រួយបារម្ភថា ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីត្រូវបានចេញ ដោយពុំបានស្នើសុំទស្សនយោបល់ពីភាគី ។ ទោះបីជាតាមការយល់តាមន័យត្រង់លើវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង វាមានន័យថា អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិយ៉ាងធំធេងនៅក្នុងការសម្រេចតាមគំនិតផ្តួចផ្តើមរបស់ខ្លួនថា រឿងក្តីមួយជាក់លាក់គួរត្រូវបានបំបែក ហើយរឿងក្តីដែលត្រូវបានបំបែកនេះគួរត្រូវបានជំនុំជម្រះតាមលំដាប់លំដោយយ៉ាងដូចម្តេចនោះក៏ដោយ វិធាននេះពុំបានផ្តល់ឆន្ទានុសិទ្ធិធំធេងដូចគ្នានៅក្នុងការសម្រេចថាតើរឿងក្តីដែលត្រូវបានបំបែកនេះគួរធ្វើឡើងតាមទម្រង់បែបណាឡើយ ជាពិសេសដោយពុំបានស្តាប់ភាគីទាំងឡាយលើបញ្ហានេះជាមុនសិន។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ឆន្ទានុសិទ្ធិបែបនេះពុំត្រូវបានពិចារណាជិតដល់ជាពិសេស នៅក្នុងសំណុំរឿងធំធេង និងស្មុគស្មាញដូចសំណុំរឿង ០០២ នេះ ដែលទម្រង់នៃការបំបែកកិច្ចដំណើរការនីតិវិធីមានផលប៉ះពាល់ធំធេង និងខ្លាំងក្លាដោយជៀសពុំរួចលើភាគីដែលមានមានការជាប់ពាក់ព័ន្ធ។ ក្នុងការពិចារណាលើឆន្ទានុសិទ្ធដែល ចែងក្នុងមាត្រា ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ដែលមិនបានបញ្ចូលនូវភាពចាំបាច់ក្នុងការស្តាប់ទស្សនះរបស់ ភាគីលើលក្ខខណ្ឌនៃការបំបែកកិច្ចដំណើរការនីតិវិធីនេះ ជាពិសេសនៅក្នុងសំណុំរឿងដែលមានទំហំធំ ដូចសំណុំរឿង ០០២ ការធ្វើដូចនេះគឺជាការចាត់ទុកឆន្ទានុសិទ្ធិនេះ គ្មានដែនមានកំណត់ ហើយផ្ទុយទៅនឹង គោលការណ៍ចម្បងនៃការបកស្រាយ ដែលមានចែងក្នុងវិធាន ២១ (១) នៃវិធានផ្ទៃក្នុង[100]។

---

[98] ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៦។

[99] *សូមមើលផ្នែកខាងលើ,* ផ្នែកទី ២ (បទដ្ឋាននៃការពិនិត្យឡើងវិញដោយអង្គជំនុំជម្រះតុលាការកំពូល)។

[100] វិធាន ២១(១) នៃវិធានផ្ទៃក្នុង ចែង *ក្នុងចំណោមនោះ*ថា "ច្បាប់ជាធរមានរបស់ អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ត្រូវតែបកស្រាយ ដើម្បីការពារនូវអត្ថប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ហើយត្រូវធានាជានិច្ចអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈ

41. អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ផងដែរចំពោះការកង្វះនូវសំអាងហេតុ នៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធី។ នៅក្នុងការបំបែកសំណុំរឿង ០០២ និង ការធ្វើគម្រោងលើវិសាលភាពដែលវំពឹងទុកនៃសំណុំរឿង ០០២/០១, អង្គជំនុំជម្រះសាលាដំបូងផ្តល់សំអាងហេតុថា ខ្លួន"បានសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ដើម្បីជាប្រយោជន៍យុត្តិធម៌"[101] ហើយថា "ការបំបែក កិច្ចដំណើរការនីតិវិធីនឹងអាចឱ្យអង្គជំនុំជម្រះចេញសាលក្រមបន្ទាប់ពីការជំនុំជម្រះដ៏ខ្លីរួច ការពារនូវអត្ថប្រយោជន៍ជាមូលដ្ឋានរបស់ជនជាប់ចោទ ក្នុងការទទួលបានយុត្តិធម៌ប្រកបដោយមានអត្ថន័យ និងទាន់ពេល ហើយនិងសិទ្ធិរបស់ជនជាប់ចោទទាំង អស់ក្នុងការទទួលបានការជំនុំជម្រះបានឆាប់រហ័ស"[102]។ ការបំភ្លឺមួយចំនួនទៀតបានលើកឡើងក្នុងសេចក្តីសម្រេចស្តីពីការពិចារណាឡើងវិញ លើចេតនារបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចេញដីកាបំបែកកិច្ចដំណើរការនីតិវិធី[103]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ការបំភ្លឺនេះកម្រិតត្រឹមការលើកឡើងវិញនូវក្នុងន័យទូទៅ ហើយមិនបានបង្ហាញថាតើ ការបំបែកនេះផ្តល់ប្រយោជន៍យុត្តិធម៌យ៉ាងណា ថែមទាំងមិនបានគោរពសិទ្ធិក្នុងការទទួលបានសេចក្តីសម្រេចមួយដែលមានសំអាងហេតុពេញលេញ[104]។

42. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះតុលាការកំពូលពុំរកឃើញមូលដ្ឋានគាំទ្រណាមួយ ចំពោះការអះអាងរបស់អង្គជំនុំជម្រះសាលាដំបូងដែលលើកឡើងថា អ.វ.ត.ក គឺជា "[ប្រព័ន្ធ] មួយដែលពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបអង្កេតត្រូវបានគ្រប់គ្រង ដោយសមត្ថកិច្ចតុលាការ"[105]។ ការអះអាងមួយបែបនេះពុំបានពិចារណាលើលក្ខណៈចម្រុះនៃយុត្តិសាស្ត្រ*ដោយឡែក*របស់

---

ពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចដែលមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង"។

[101] ដីកាបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៥។

[102] ដីកាបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៨។

[103] *សូមមើល* សេចក្តីសម្រេចលើការពិចារណាឡើងវិញ កថាខណ្ឌ ១០។

[104] សូមមើលសេចក្តីសម្រេចទាក់ទងនឹង វិធាន ៣៥ កថាខណ្ឌ ២៥។

[105] សេចក្តីសម្រេចលើសំណើសុំឱ្យពិចារណាឡើងវិញ កថាខណ្ឌ ៤។ នៅក្នុងបរិបទរបស់ អ.វ.ត.ក ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានគ្រប់គ្រងដោយតុលាការដែល ថាសេហាចៅក្រមស៊ើបអង្កេត "បញ្ចប់កិច្ចស៊ើបសួរដោយចេញដីកាដំណោះស្រាយ និងដោយចោទប្រកាន់ជនត្រូវចោទ ហើយបញ្ជូនជនោះទៅជំនុំជម្រះ ឬ បដិសេធចោលសំណុំរឿងនោះ" ហើយ"ចៅក្រមស៊ើបអង្កេតមិនត្រូវបានចងកាតព្វកិច្ចដោយដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាឡើយ"។ *សូមមើល*វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង។ *សូមមើល*មាត្រា ២៤៦ ដល់ ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ចៅក្រមនៃអង្គបុរេជំនុំជម្រះ មានយុត្តាធិការក្នុងការគ្រប់គ្រងលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលទទួលបានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។

អ.វ.ត.ក នោះទេ ហើយការអះអាងនេះទៀតសោតក៏ពុំបានយកចិត្តទុកដាក់ចំពោះបទប្បញ្ញត្តិ ដែលយោងយ៉ាងជាក់លាក់លើលក្ខណៈចំពោះមុខនៃកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ព្រមទាំងលើតួនាទី និងការទទួលខុសត្រូវដ៏សំខាន់របស់សហព្រះរាជអាជ្ញានៅក្នុងការធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងការបង្ហាញបទចោទនៅក្នុងដីកានោះផងដែរ[106]។ បើទោះជា អ.វ.ត.ក អាចត្រូវបានគេនិយាយថា បានដំណើរការស្របតាមប្រព័ន្ធពាក់ព័ន្ធនឹងកិច្ចស៊ើបសួរយ៉ាងតឹងរ៉ឹងមួយក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញមូលដ្ឋានណាមួយចំពោះការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងថា ប្រព័ន្ធនេះពុំចាំបាច់ទាមទារឱ្យស្នើសុំទស្សនយល់ឃើញរបស់សហព្រះរាជអាជ្ញា (ឬ ភាគីផ្សេងទៀត) អំពីការបំបែករឿងក្ដីនេះឡើយ ឬ ក្នុងការពិចារណាថាតើរឿងក្ដីដែលត្រូវបានបំបែកនេះ បានតំណាងដីកាបញ្ជូនរឿងទៅជំនុំជម្រះយ៉ាងសមហេតុសមផលដែរ ឬយ៉ាងណា។ ភាពចាំបាច់ក្នុងការគោរពសិទ្ធិទទួលបានការជំនុំជម្រះនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ និងការពិចារណាលើលទ្ធភាពក្នុងការបំបែកសំណុំរឿងព្រហ្មទណ្ឌដែលសំណុំរឿងនេះត្រូវតំណាងយ៉ាងសមហេតុផលឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងជាផលប្រយោជន៍យុត្តិធម៌ដ៏មានអត្ថន័យ និងស្របទៅតាមបទដ្ឋានគតិយុត្តអន្តរជាតិដែលមានលក្ខណៈប្រហាក់ប្រហែល[107]។

---

សូមមើលវិធាន ៦៩(១)នៃវិធានផ្ទៃក្នុង។ *សូមមើល*មាត្រា ១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ក្រោយពីបានបញ្ចប់តួនាទីរបស់សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ទទួលបាន ដីកាបញ្ជូនរឿងទៅជំនុំជម្រះសម្រាប់ការរៀបចំសវនាការ។ សូមមើល វិធាន៧៩ នៃវិធានផ្ទៃក្នុង។

[106] *សូមមើល ឧ.* វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង ("ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ នីតិវិធីត្រូវធានាឱ្យបាននូវភាពដាច់ ដោយឡែកពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និងអាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស")។ វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង ("សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ ")។ មាត្រា ១៦ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែលបានធ្វើវិសោធនកម្ម និងប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤("ច្បាប់ អ.វ.ត.ក") ("រាល់ការសន្និដ្ឋានចោទប្រកាន់ជូនទៅ [អ.វ.ត.ក] គឺជាការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញាពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀត ជាបរទេស ដែលហៅថា "សហព្រះរាជអាជ្ញា" ដែលត្រូវធ្វើការរួមគ្នាដើម្បីរៀបចំឯកសារ និងធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ជនសង្ស័យសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ")។ *សូមមើល* មាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("ព្រះរាជអាជ្ញា ជាចាប់ផ្ដើមកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ហើយស្នើសុំការអនុវត្តច្បាប់ដោយចៅក្រមស៊ើបអង្កេត និងចៅក្រមជំនុំជម្រះ")។*សូមមើលផងដែរ* មាត្រា ៣៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ("[អង្គជំនុំជម្រះវិសាមញ្ញ] របស់សាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន")។

[107] សូមប្រៀបធៀបវិធាន ៧៣ស្ទួន(ឃ) នៃវិធានរបស់តុលាការ ICTY, *ការដកស្រង់នៅផ្នែកខាងលើ*កថាខណ្ឌ ៩៥។

43. ដូចគ្នានេះដែរ យុត្តិកម្មបន្ថែមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងការច្រានចោលសញ្ញាណដែលលើកឡើងថា សំណុំរឿង ០០២/០១ គួរតែតំណាងខ្លាំងជាងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ ពោលគឺ“ការចោទប្រកាន់ ឬ បទចោទនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមានទំនាក់ទំនងបន្តបន្ទាប់គ្នានៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនោះ”[108] វាពុំមានលក្ខណៈសមហេតុសមផលដូចគ្នា នៅពេលពិចារណាលើហេតុផលជាក់លាក់ នៅក្នុងការបង្គាប់ឱ្យបំបែកកិច្ចដំណើរការនីតិវិធីតាំងពីដំណាក់កាលដំបូង។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា យុត្តិកម្មបែបនេះពុំស៊ីសង្វាក់គ្នាទៅនឹងការអះអាងរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្ដីសម្រេចដដែលនេះថា “ដោយពិចារណាថា ពិតជាមានក្ដីបារម្ភមួយថាតើ ជនជាប់ចោទនឹងអាចចូលរួមទាំងផ្លូវកាយ និងស្មារតីនៅក្នុងការជំនុំជម្រះដែលមានរយៈពេលវែង ឬ យ៉ាងណា ដូចដែលសហព្រះរាជអាជ្ញាលើកឡើងនោះ អង្គជនុំជម្រះបានចាត់ទុកវិធានការទាំងនេះថាមានសារៈសំខាន់ដើម្បី “[ការពារ] ផលប្រយោជន៍ជាសារវ័ន្តរបស់ជនរងគ្រោះក្នុងការទទួលបាននូវយុត្តិធម៌ប្រកបដោយអត្ថន័យ និងទាន់ពេលវេលា ព្រមទាំងការពារបាននូវសិទ្ធិរបស់ [សហ] ជនជាប់ចោទទាំងអស់ក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័សនៅក្នុងសំណុំរឿង ០០២ ទៀតផង”[109]។ ទោះបីជាដូច្នេះមែន វិមតិសង្ស័យរបស់អង្គជំនុំជម្រះសាលាដំបូងអំពីលទ្ធភាពរបស់សហជនជាប់ចោទនៅក្នុងការចូលរួមការជំនុំជម្រះ ដែលមានរយៈពេលវែងមួយដូច្នេះ វាពុំទំនងអាចស្វែងរកវិធីណាមួយដើម្បីកំណត់វិសាលភាពនៃសំណុំរឿង ០០២/០១ នៅក្នុងដំណាក់កាលដំបូងបំផុត ដែលអាចពង្រីកឱ្យបានកម្រិតអតិបរមានូវបទចោទទាំងអស់ប្រឆាំងនឹងជនជាប់ចោទ និងដែលអាចផ្ដល់ឱកាសនៅក្នុងការទទួលបានយុត្តិធម៌ដ៏មានអត្ថន័យពេញលេញ នៅក្នុងរយៈពេលមួយដ៏ខ្លីបំផុត។

44. យោងតាមហេតុផលទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយវិធាន ៨៩*ស្ទួន* នៃវិធានផ្ទៃក្នុងដែលវិធានេះបានផ្ដល់ឆន្ទានុសិទ្ធិក្នុងការបំបែកសំណុំរឿង ០០២ ដោយពុំចាំបាច់ផ្ដល់សំអាងហេតុគ្រប់គ្រាន់ ដែលបង្ហាញពីអត្ថប្រយោជន៍នៃយុត្តិធម៌ដែលតម្រូវ ហើយដោយមិនចាំបាច់ស្នើសុំយោបល់ពីភាគីនានាលើលក្ខខណ្ឌនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសដែលស្ដែងឱ្យឃើញតាមរយៈការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន នៅពេលចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដោយពុំបាន

---

[108] សេចក្ដីសម្រេចលើសំណើសុំឱ្យពិចារណាឡើងវិញ កថាខណ្ឌ ៩។

[109] សេចក្ដីសម្រេចលើសំណើសុំឱ្យពិចារណាឡើងវិញ កថាខណ្ឌ ១១ *ដោយយោងលើ*ដីកាបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៨។

អញ្ជើញភាគីឱ្យដាក់សេចក្តីសន្និដ្ឋានអំពីលក្ខខណ្ឌនៃការបំបែកកិច្ចដំណើរការនីតិវិធី និងនៅពេលចេញសេចក្តីសម្រេចលើសំណើសុំឱ្យពិចារណាឡើងវិញ ដោយពុំបានពិចារណាលើនីតិវិធីនៅក្នុងការធ្វើយ៉ាងណាឱ្យវិសាលភាពនៃសំណុំរឿង ០០២/០១ តំណាងដីកាបញ្ជូនរឿងទៅជំនុំជម្រះមានលក្ខណៈសមស្របឡើយ។ នៅពេលរំលោភលើសិទ្ធិទទួលបានទស្សនយោបល់ និងសិទ្ធទទួលបានការជំនុំជម្រះ និងនៅពេលកម្រិតវិសាលភាពនៃសំណុំរឿង ០០២/០១ នៅក្នុងវិធីមួយ ដែលពុំបានពិចារណាលើភាពតំណាងឱ្យបានសមស្របនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានធ្វើឱ្យប៉ះពាល់ប្រយោជន៍របស់សហព្រះរាជអាជ្ញា[110]។

---

[110] ទោះបីសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនមែនជាភាគីនៃបណ្តឹងសាទុក្ខក្នុងសំណុំរឿងបច្ចុប្បន្ននេះក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ដូចគ្នា ប្រសិនបើមិនធ្ងន់ធ្ងរទេនោះ ថាមានាការរំលោភសិទ្ធិក្នុងការទទួលបានការជំនុំជម្រះ។ នៅថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១១ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជូនដំណឹងថា ខ្លួនក៏មានបំណងស្នើសុំការពិចារណាឡើងវិញលើដីកាបំបែកសំណុំរឿងនេះដែរ។ សូមមើល ការជូនដំណឹងអំពីសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំការពិចារណាឡើងវិញ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សំណើរបស់ខ្លួននៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ វេលាម៉ោង ១៣ និង ៤៩ នាទី។ *សូមមើល* សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំការពិចារណាឡើងវិញ ទំព័រទីមួយ។ សេចក្តីសម្រេចស្តីពីការពិចារណាឡើងវិញ ត្រូវបានដាក់បីម៉ោងក្រោយមក នៅវេលាម៉ោង ១៦ និង ៣៥ នាទី។ *សូមមើល* សេចក្តីសម្រេចស្តីបីការពិចារណាឡើងវិញ ទំព័រទីមួយ។ នៅក្នុងសេចក្តីសម្រេចស្តីពីការពិចារណាឡើងវិញ អង្គជំនុំជម្រះសាលាដំបូង ទទួលយកការជូនដំណឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីសំណើសុំការពិចារណាឡើងវិញ (*សូមមើល*សេចក្តីសម្រេចស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ១) ប៉ុន្តែមិនបានដោះស្រាយលើទឡ្ហីករណ៍ណាជាក់លាក់ឡើយ។ បន្ទាប់ពីនេះទៀត សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំថា អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចដោយ មានសំអាងហេតុលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំការពិចារឡើងវិញនេះ។ *សូមមើល*សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំការបំភ្លឺ និងសេចក្តីសម្រេចមានសំអាងហេតុ។ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា "ទោះបីជាមានការជូនដំណឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីសំណើសុំការពិចារណាឡើងវិញក៏ដោយ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនស្តីពីការពិចារណាឡើងវិញ បំភ្លឺថា ខ្លួនបានសម្រេចលើ(សំណើរបស់សហព្រះរាជអាជ្ញា សុំការពិចារណាឡើងវិញ) ឱ្យបានឆាប់រហ័ស ដើម្បីការពារនូវលទ្ធភាពរបស់ខ្លួនក្នុងការចាប់ផ្តើមការជំនុំជម្រះលើអង្គសេចក្តីក្នុងសំណុំរឿង ០០២ ក្នុងឆ្នាំ ២០១១ (...)។ អង្គជំនុំជម្រះបានបន្តទៀតថា សេចក្តីសម្រេចដាច់ដោយឡែក(ទៅលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំការពិចារណាឡើងវិញ និងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំការបំភ្លឺ និងសេចក្តីសម្រេចមានសំអាងហេតុ មិនមានលក្ខខណៈចាំបាច់ឡើយ ដោយសំណើទាំងនេះមានលក្ខណៈដូចគ្នានឹងខ្លឹមសារលើបញ្ហាដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចមកហើយ(ក្នុងសេចក្តីសម្រេចស្តីពី ការពិចារណាឡើងវិញ)។ សំណើបន្ថែមដែលស្នើសុំការពិចារណាឡើងវិញលើដីកាបំបែកកិច្ចដំណើរការនីតិវិធី ថាតើមានទម្រង់ជាសំណើសុំការបំភ្លឺ , សារណាតប ឬអ្វីប្រហាក់ប្រហែលនោះនឹងទទួលបានការឆ្លើយតបពីអង្គជំនុំជម្រះសាលាដំបូងឡើយ ហើយអាចត្រូវបានចាត់ទុកថា ជាការប៉ុនប៉ងដោយចេតនាដើម្បីពន្យារពេលកិច្ចដំណើរការនីតិវិធី"។ *សូមមើល* អនុស្សរណៈចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ១ ដល់ ២។ ទោះបីជា

45. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ផលប៉ះពាល់បែបនេះត្រូវបានកែតម្រូវមួយផ្នែក នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានអញ្ជើញភាគីទាំងអស់ឱ្យដាក់សេចក្ដីសន្និដ្ឋានអំពីហានិភ័យ និងផលប្រយោជន៍នៅក្នុងសំណើសុំឱ្យដាក់បញ្ចូលបន្ថែម រួមទាំង ផលប៉ះពាល់លើសិទ្ធិ និងផលប្រយោជន៍របស់ភាគីនីមួយៗ ក្រោយពីទទួលបានសំណើសុំពង្រីកវិសាលភាពនេះ[111]។ ទោះបីជាយ៉ាងនេះក្ដី សវនាការដែលមានរយៈពេលជិតមួយឆ្នាំ បានកន្លងផុតទៅហើយ លើអង្គសេចក្ដីដោយគោរពតាមលក្ខខណ្ឌនៃដីកាបំបែកកិច្ចដំណើរការនីតិវិធីនេះ[112] ដោយបានធ្វើឱ្យវិសាលភាពនៃសំណុំរឿង ០០២/០១ ចេញជារូបរាងយ៉ាងប្រសិទ្ធិភាព។ លើសពីនេះទៀត សេចក្ដីសម្រេចដែលរងការជំទាស់ ពុំបានលើកឡើងអំពីករណីថាតើអង្គជំនុំជម្រះសាលាដំបូងបានផ្លាស់ប្ដូរទស្សនយល់ឃើញរបស់ខ្លួន ដែរ ឬយ៉ាងណា អំពីបញ្ហាវិសាលភាពនៃសំណុំរឿង ០០២/០១ គួរតំណាងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលជាសំណើមួយរបស់ សហព្រះរាជអាជ្ញាដែលបានលើកឡើងបញ្ជាក់ជាថ្មីម្ដងទៀត នៅក្នុងសំណើសុំពង្រីកវិសាលភាពនេះ[113] នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចដាក់បញ្ចូលទួលពោធិ៍ជ្រៃ ប៉ុន្តែ មិនដាក់បញ្ចូលស្រុក ១២ និងមន្ទីរ ស ២១។ ផ្ទុយមកវិញ សេចក្ដីសម្រេចដែលត្រូវបានជំទាស់បន្តផ្អែកលើមូលដ្ឋានយ៉ាងខ្លាំងលើសេចក្ដីពិចារណាអំពីភាពឆាប់រហ័សតែប៉ុណ្ណោះ ដោយគ្រាន់តែបន្ថែមសំអាងហេតុថា ការកាប់សម្លាប់នៅទួលពោធិ៍ជ្រៃ "គឺជាការពង្រីកវិសាលភាពសមស្របនៃការចោទប្រកាន់ដែលមានស្រាប់ក្នុងសំណុំរឿង ០០២/០១"[114] ខណៈដែល តាមទស្សនយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ការកាប់សម្លាប់នៅស្រុក ១២ និងមន្ទីរ ស ២១ ពុំដូច្នេះនោះទេ[115]។ ជាផលវិបាក គេអាចត្រឹមតែសន្មតថា នៅក្នុងសេចក្ដី

យ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសុំការពិចារណាឡើងវិញមានការបារម្ភមួយចំនួនដែលសំខាន់ ដែលទាក់ទងទៅនឹងផលប្រយោជន៍ជាក់លាក់ ដែលសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីចងបង្ហាញ ហើយ ដែលមិនត្រូវបានលើកឡើងនៅក្នុងសំណើរបស់សហព្រះរាជអាជ្ញាសុំការពិចារណាឡើងវិញ។ *សូមមើល ឧ.* សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសុំការពិចារណាឡើងវិញ កថាខណ្ឌ ២ ដល់ ២១, ៣២, ៣៥ ដល់ ៤២, និង ៤៥។ សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសុំការបំភ្លឺ និងសេចក្ដីសម្រេចមានសំអាងហេតុ កថាខណ្ឌ ៦ ដល់ ១១។ ការបារម្ភទាំងនេះ ពុំទាន់ត្រូវបានដោះស្រាយនៅឡើយរហូតដល់ពេលបច្ចុប្បន្ននេះ។

[111] អនុស្សរណៈចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ១៣-១៥។

[112] សេចក្ដីថ្លែងបើក ចាប់ផ្ដើមនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១។ *សូមមើល* ប្រតិចារិក ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E1/13.1 (ការជំនុំជម្រះថ្ងៃទី ១)។

[113] សំណើសុំបញ្ចូលបន្ថែម កថាខណ្ឌ ៥ កថាខណ្ឌ ១៥-២០។

[114] សេចក្ដីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣។

[115] សេចក្ដីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២។

សម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះសាលាដំបូងនៅតែផ្អែកសេចក្តីសម្រេចនេះ តាមរយៈបទដ្ឋានមិនបានបង្ហាញច្បាស់លាស់ ជាជាងតាមរយៈទំនាក់ទំនងដែលមានលំដាប់លំដោយក្នុងចំនោមបទចោទជាក់លាក់ទាំងនេះ។

46. គួរកត់សម្គាល់ផងដែរថា ការអញ្ជើញរបស់អង្គជំនុំជម្រះសាលាដំបូងឲ្យដាក់សារណាលើវិសាលភាពនៃសំណុំរឿង ០០២/១ និងសេចក្តីសម្រេចរបស់ខ្លួនបដិសេធការពង្រីកវិសាលភាពមួយផ្នែកធំ ដែលរងការជំទាស់នេះ បានចេញប្រហែលមួយឆ្នាំ ក្រោយការចេញដីកាបំបែកសំណុំរឿង។ ទន្ទឹមនឹងនេះ អង្គជំនុំជម្រះសាលាដំបូងបានដាក់ដែនកំណត់នៃវិសាលភាពសំណុំរឿង ០០២/០១ នេះក្នុងស្ថានភាពមួយមិនប្រាកដប្រជា[116] ហើយអង្គជំនុំជម្រះសាលាដំបូងក៏មិនបានដាក់ចេញនូវផែនការណាមួយជាក់ស្តែងពាក់ព័ន្ធនឹងចំនួន ឬវិសាសភាពនៃសំណុំរឿងសេសសល់ដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង ០០២ នេះទេ[117]។ ស្ថានភាពមិនច្បាស់លាស់នេះនៅតែបន្តរហូតដល់ពេលនេះ បើទោះបីមានការបញ្ជាក់ពីអង្គជំនុំជម្រះសាលាដំបូងក្នុងដីកាបំបែកសំណុំរឿងរបស់ខ្លួនថា "ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងសំណុំរឿង ដែលត្រូវយកមកជំនុំជម្រះបន្តបន្ទាប់ទៀតក្នុងកិច្ចដំណើរការក្តីលើសំណុំរឿង ០០២ នឹងត្រូវផ្តល់ជូនដល់ភាគី និងសាធារណជនក្នុងពេលវេលាសមស្របដែលអាចធ្វើទៅបាន" យ៉ាងណាក្តី[118]។

47. អ.វ.ត.ក មានកាតព្វកិច្ចក្នុងការធានាថា កិច្ចដំណើរការនីតិវិធីត្រូវធ្វើឡើងតាមពេលវេលាសមស្រប[119]។ ប៉ុន្តែ ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងដែលចេះតែកើតមាននេះ ក្នុងការទូវផែន ការសម្រាប់ការជំនុំជម្រះដែលនៅសេសសល់នាពេលអនាគត ក្នុងសំណុំរឿង ០០២ បណ្តាលឱ្យមានការ ភ័ន្តច្រឡំដល់ភាគីនានា ហើយបាន"ដីកកប់"យ៉ាងមានប្រសិទ្ធិភាពនូវបទចោទដែលនៅសេសសល់នៅក្នុងដីកាបញ្ជូនរឿងជំនុំជម្រះទាំងនោះចោល។ ខណៈដែលអង្គជំនុំជម្រះសាលាដំបូង ប្រកាសពីចេតនារបស់ខ្លួនក្នុងការចាប់ផ្តើមសំណុំរឿងបន្តទៀតក្នុងពេលឆាប់ៗនោះ ក្រោយពីការបញ្ចប់ លើភស្តុតាងក្នុងសំណុំរឿង ០០២/០១ ក្នុងឆ្នាំ ២០១៣[120] ហើយ ថា កិច្ចដំណើរការនីតិវិធីបន្តបន្ទាប់នេះ អាចចាប់ផ្តើមមុនពេល

---

[116] *សូមមើល*កថាខណ្ឌ១៧ ៣៧ ខាងលើ និងជើងទំព័រ៤៦។

[117] *សូមមើល*កថាខណ្ឌ២៣-២៤ខាងលើ និងជើងទំព័រ៦៣។

[118] សូមមើលដីកាបំបែកសំណុំរឿង កថាខណ្ឌ ៤។

[119] សូមមើល វិធាន ២១(៤) នៃវិធានផ្ទៃក្នុង ("កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ត្រូវបញ្ចប់ទៅតាមពេលវេលាសមស្រប")។

[120] អនុស្សរណៈចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ១។

ការបញ្ចប់នៃបណ្តឹងសាទុក្ខនានាក្នុងសំណុំរឿង ០០២/០១[121]នោះ មានការបារម្ភជាក់ស្តែងជាច្រើនដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា[122] និង សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី[123] ដែលពុំទាន់បានដោះស្រាយ ដែលអាចរារាំងដល់ការជំនុំជម្រះក្តីនាពេលអនាគតតាមពេលវេលាសមស្រប។ ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណា ឃើញថា ការប៉ះពាល់ផលប្រយោជន៍នេះកើតចេញពីការខកខានរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការ បញ្ជាក់ពីផែនការសម្រាប់ការជំនុំជម្រះនាពេលអនាគតក្នុងសំណុំរឿង ០០២។

## V. សេចក្តីសន្និដ្ឋាន

48. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គច្បាប់ ក្នុងការបកស្រាយដែននៃយុត្តាធិការរបស់ខ្លួនអនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ដែលការបកស្រាយនេះមិនបានគិតពីភាពចាំបាច់ក្នុងការបង្ហាញ ជាសំអាងហេតុគ្រប់គ្រាន់នូវអត្ថប្រយោជន៍យុត្តិធម៌ក្នុងការបំបែកសំណុំរឿង ០០២ ក៏ដូចជាភាពចាំបាច់ក្នុងការស្តាប់ភាគីនានាក្នុងសំណុំរឿង ០០២ ស្តីអំពីលក្ខខណ្ឌនៃការបំបែកនីតិវិធីនេះ។ ការចេញ ដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង និងសេចក្តីសម្រេចស្តីពីការធ្វើការពិចារណាឡើងវិញ ដោយសំអាងលើការបកស្រាយដោយមានកំហុស របស់ខ្លួនលើវិធាន *៨៩ស្ទួនពីរ* នៃវិធានផ្ទៃក្នុង គឺជាការរំលោភដល់សិទ្ធិរបស់ភាគីក្នុងការទទួលបានយោបល់ដែលមានសំអាងហេតុ និងការជំនុំជម្រះ និងរួមទាំងកំហុសក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដែលបណ្តាលឱ្យមានការប៉ះពាល់ដល់សិទ្ធិ។ ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបង្កើតផែនការទាក់ទងនឹងការដោះស្រាយសំណុំរឿងដែលនៅសេសសល់ដើម្បីជំនុំជម្រះក្នុងសំណុំរឿង ០០២ ក៏ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិផងដែរ។

49. អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ពីវិសាលភាព និងភាពស្មុគស្មាញនៃសំណុំរឿង ០០២ រួមទាំងលក្ខខណ្ឌសុខភាពរបស់ជនជាប់ចោទដែលចេះតែដុនដាបទៅៗ ដែលញ៉ាំងឱ្យអង្គជំនុំជម្រះសាលាដំបូងបំបែកកិច្ចដំណើរការនីតិវិធីទៅជាការជំនុំជម្រះដែលមានលក្ខណៈឆាប់រហ័ស និងងាយស្រួល

[121] សេចក្តីសម្រេចលើការពិចារណាឡើងវិញ កថាខណ្ឌ ៧ ដល់៨។

[122] សូមមើលបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ១៨។ *សូមមើលផងដែរ* សំណើសុំការពិចារណាឡើងវិញ កថាខណ្ឌ ២៦ ដល់ ២៨។

[123] សំណុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំការពិចារណាឡើងវិញ កថាខណ្ឌ ២៥ ដល់ ៣២។

រៀបចំ។ ជាការពិត សេដ្ឋកិច្ចនៃយុត្តិធម៌ អាចត្រូវបានបម្រើតាមរយៈកិច្ចដំណើរការនីតិវិធីរហូតដល់សាលក្រម លើបញ្ហាមួយចំនួន មុនពេលចាប់ផ្តើមជំនុំជម្រះលើបញ្ហាដ៏ទៃទៀត ហើយអត្ថប្រយោជន៏នេះ អាចធ្វើយុត្តិកម្មបានដោយការពិចារណាផ្នែកស្ថាប័ន ក៏ដូចជាផ្លូវច្បាប់។ ប៉ុន្តែ ទាំងអស់នេះ ពុំត្រូវបានពន្យល់យ៉ាងក្បោះក្បាយទាក់ទងនឹងសំណុំរឿង ០០២ ទាំងមូល។ ក្នុងន័យនេះ អនុភាពនៃកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងដែលត្រួតលើគ្នា ក្នុងការធ្វើឱ្យការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០១ បណ្តាលឱ្យដីការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ នេះ មោឃភាព ដែលមានដីកាបំបែកកិច្ចដំណើរការនីតិវិធី សេចក្តីសម្រេចស្តីពីការពិចារណាឡើងវិញ និងសេចក្តីសម្រេចដែលរងការជំទាស់ រួមជាមួយនឹងអនុស្សរណៈពាក់ព័ន្ធទាំងឡាយ[124]ត្រូវបដិសេធចោលដូចគ្នា។ ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា សេចក្តីសម្រេចដែលរងការជំទាស់នេះ ត្រូវចាត់ទុកជាមោឃៈ។ បញ្ហានៃការកែប្រែសេចក្តីសម្រេចនេះ ដើម្បីបញ្ចូល ស្រុក ១២ និង ស ២១ នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ចាត់ទុកជាអាសាបង់។

50. សេចក្តីសម្រេចនេះ ពុំបានធ្វើឱ្យប៉ះពាល់ដល់វាយតម្លៃឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកសំណុំរឿង ០០២ ដោយអនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង។ ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូងបន្តពិចារណាលើអត្ថប្រយោជន៍យុត្តិធម៌ ដែលតម្រូវឱ្យបំបែកសំណុំរឿង ០០២ នោះ ជាបូង អង្គជំនុំជម្រះត្រូវអញ្ជើញភាគីនានាដាក់សារណារបស់លើលក្ខខណ្ឌនៃដីកានេះ ហើយនៅពេល ដែលអត្ថប្រយោជន៍របស់ភាគី *ទាំងអស់*ត្រូវបានធ្វើឱ្យមានតុល្យភាពចំពោះកត្តាពាក់ព័ន្ធផ្សេងៗហើយនោះ ការបំបែកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ អាចធ្វើទៅបានប្រកបដោយភាពសមស្រប។ ជាការចាំបាច់ណាស់ថា អង្គជំនុំជម្រះសាលាដំបូងត្រូវកំណត់ ដោយសំអាងលើការស្គាល់ជាខ្លឹមសារលើសំណុំរឿង ០០២ លើបញ្ហាថាតើ អត្ថន័យនៃការបំបែកនេះ គឺស្ថិតក្រោមការរៀបចំរបស់តុលាការដែរ ឬ យ៉ាងណា ក្នុងករណីនេះ មានភាពចាំបាច់សម្រាប់បង្កើតផែនការច្បាស់លាស់ជាក់ស្តែងសម្រាប់ការជំនុំជម្រះលើបទចោទ ទាំងមូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយមិនត្រឹមតែផ្តល់ព័ត៌មានជាផ្នែកតូចនោះទេ។ ប៉ុន្តែ ប្រសិនបើ នៅពេលប្រឈមមុខនឹងបញ្ហាសុខភាពរបស់ជនជាប់ចោទចេះតែដុនដាបទៅការជំរុញទឹកចិត្តគឺថា ត្រូវតែផ្តល់យុត្តិធម៌ឱ្យបានប្រសើរជាង តាមរយៈការបញ្ចប់ជាមួយនឹង ការចេញសាលក្រម ទោះក្នុងករណីដាក់ពិរុទ្ធ ឬដោះលែង យ៉ាងហោចណាស់ លើការជំនុំជម្រះតូចមួយនៃផ្នែកខ្លះៗ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូង គប្បីបញ្ជាក់ច្បាស់លាស់ និងផ្តល់

---

[124] សូមមើផ្នែកខាងលើ កថាខណ្ឌ ១៧ និង ៣៧។

ការពិចារណាសមស្របទៅលើការតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅជាការជំនុំជម្រះតូចជាងនេះ[125]។

51. នៅក្នុងដំណាក់កាលនេះ អង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាថា មានអង្គចៅក្រមជំនុំជម្រះតែមួយ មិនអាចបំពេញកាតព្វកិច្ចរបស់ អ.វ.ត.ក ក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធីលើបទចោទទាំងមូល នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះតាមពេលវេលាសមស្របបាននោះទេ។ អាស្រ័យហេតុនេះ ក្នុងករណីមានការបន្តការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អ.វ.ត.ក គប្បីបង្កើតត្រូវមានអង្គចៅក្រមជំនុំជម្រះមួយទៀតនៅក្នុងអង្គជំនុំជម្រះ ដើម្បីគាំទ្រដល់ការជំនុំជម្រះឱ្យបានទាន់ពេលទៅលើផ្នែកដែលនៅសេសសល់នៃសំណុំរឿង ០០២[126]។ ការបង្កើតអង្គចៅក្រមជំនុំជម្រះទីពីរ នឹងអាចការពារបានចំពោះការបារម្ភណាមួយទៅលើភាពលំអៀងដែលទំងនងជាមាន ឬក៏ភាពលំអៀងជាក់ស្តែងរបស់ចៅក្រមនៅក្នុងការជំនុំជម្រះទីមួយ ដែលមកកាត់សេចក្តីលើការជំនុំជម្រះទីពីរ[127]។ អង្គជំនុំជម្រះសាលាដំបូងទីពីរនេះ អាចចាប់ផ្តើមភ្លាមៗលើកិច្ចដំណើរការនីតិវិធីបន្ទាប់ទៀត ក្នុងខណៈដែលអង្គជំនុំជម្រះសាលាដំបូង កំពុងជាប់រវល់ជាមួយនឹងការព្រាងលើសាលក្រមក្នុងសំណុំរឿង ០០២/០១ ហើយធានាបានថា ភាគីមិនទុកឱ្យទំនេរនៅក្នុងអំឡុពេលនេះ។ ដោយដឹងថា អាយុកាន់តែចាស់ និងសុខភាពរបស់ជនជាប់ចោទកាន់ធ្លាក់ចុះ ក៏ដូចជា ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែល

---

125 សូមធ្វើការប្រៀបធៀ លើសេចក្តីសម្រេចនៃ *Mladić* កថាខណ្ឌ ៣០។

126 *សូមធ្វើការប្រៀធៀប រឿងក្តី* *Parizov* *ទល់នឹង* *The Former Yugoslav Republic of Macedonia*, សំណើរបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECHR) លេខ 14258/03, សាលក្រម, ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ៥៩ (“តុលាការរំឭកថា នេះគឺសម្រាប់រដ្ឋជាប់កាតព្វកិច្ចក្នុងការ បង្កើតប្រព័ន្ធច្បាប់របស់ខ្លួន ទៅតាមវិធីមួយដែល តុលាការរបស់ខ្លួអាចធានា សិទ្ធិរបស់មនុស្សគ្រប់រូប ដើម្បីទទួលបានសេចក្តីសម្រេចជាស្ថាពរលើជម្លោះ […] ក្នុងពេលវេលាសមហេតុផល”); រឿងក្តី *Markoski* *ទល់នឹង* *The Former Yugoslav Republic of Macedonia*, សំណើរបស់តុលាការអឺរ៉ុតស្តីពីសិទ្ធិមនុស្ស លេខ 22928/03, សាលក្រម, ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ៣៩ (“តុលាការរំឭកថា បន្ទុកការងារគាំរ៉ៃ មិនអាចយកមកធ្វើយុត្តិកម្មលើរយៈពេលនៃតំណើរការនីតិវិធីដែលវែងហួសកំណត់ឡើយ”); *រឿងក្តី* *Kostovska* *ទល់នឹង* *The Former Yugoslav Republic of Macedonia*, សំណើរបស់តុលាការអឺរ៉ុតស្តីពីសិទ្ធិមនុស្ស លេខ 44353/02, សាលក្មរម, ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៦ កថាខណ្ឌ ៤១; រឿងក្តី *Dumanovski* *ទល់នឹង* *The Former Yugoslav Republic of Macedonia*, សំណើរបស់តុលាការអឺរ៉ុតស្តីពីសិទ្ធិមនុស្ស លេខ 13898/02, សាលក្រម, ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៥ កថាខណ្ឌ ៤៥ (“ដោយហេតុថា តុលាការអនុវត្តជាប្រចាំតាមច្បាប់យុត្តិសាស្ត្ររបស់ខ្លួន […], បន្ទុកការងារនៅក្នុងតុលាការជាតិ មិនអាចចាត់ទុកថា ជាកត្តដែលអាចដោះសារក្នុងការអូសបន្លាយកិច្ចដំណើរការនីតិវិធីឡើយ”)។

127 *សូមមើល*សេចក្តីសម្រេចលើ *Mladić* ។

បានចោទប្រកាន់ដែលមានសេសសល់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចនេះ ជាការតម្រូវថា អ.វ.ត.ក ដំណើរការជារឿង រាល់ថ្ងៃដែលខ្លួនអាធ្វើទៅបាន ដើម្បីធានាបាននូវការសម្រេចជាស្ថាពរលើបទចោទដែលសេសសល់ឱ្យបាន ឆាប់ដែលអាចធ្វើទៅបាន។

## VI. ផ្នែកសេចក្តីសម្រេច

52. យោងលើហេតុផលដែលបានរៀបរាប់ខាងលើ **អង្គជំនុំជម្រះតុលាការកំពូល** សម្រេច៖

**ទទួលយក**បណ្តឹងសាទុក្ខភ្លាមៗ អនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង

**ប្រកាសថា** ដីកាបំបែកសំណុំរឿង ០០២ គ្មានសុពលភាព និង

**មោឃភាព** សេចក្តីសម្រេចដែលរងការជំទាស់នេះ។

**ភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**